ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# របាយការណ៍ប្រចាំឆ្នាំ២០២០
# ស្តីពីប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា

ខែមិថុនា ឆ្នាំ២០២០

# អារម្ភកថា

ប្រព័ន្ធទូទាត់បានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពសម្រាប់សម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់ក្នុងសកម្មភាពទិញលក់ទំនិញនិងសេវា និងការជួញដូរក្នុងទីផ្សារហិរញ្ញវត្ថុ។ ជំនួសឱ្យការប្រើប្រាស់សាច់ប្រាក់ដែលចំណាយកម្រៃប្រតិបត្តិការខ្ពស់ (ចំណាយលើការដឹកជញ្ជូន និងរក្សាទុកព្រមទាំងហានិភ័យនៃការបាត់បង់ជាដើម) ប្រព័ន្ធទូទាត់បានផ្តល់នូវមធ្យោបាយងាយស្រួល សុវត្ថិភាព រហ័ស និងមានកម្រៃសមរម្យសម្រាប់ផ្ទេរមូលនិធិជាអេឡិចត្រូនិកក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ច ដែលការណ៍នេះបានរួមចំណែកឱ្យដំណើរការផ្គត់ផ្គង់រូបិយវត្ថុរបស់ធនាគារកណ្តាលកាន់តែមានប្រសិទ្ធភាព។ បន្ថែមពីនេះ តាមរយៈហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ ធនាគារកណ្តាលអាចអនុវត្តប្រតិបត្តិការទីផ្សារចំហដែលជាឧបករណ៍គោលនយោបាយរូបិយវត្ថុចម្បងក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងអាចតាមដានមើលពីស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរហ័ស ដែលជាផ្នែកមួយក្នុងការរួមចំណែកធានាស្ថិរភាពហិរញ្ញវត្ថុផងដែរ។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់ក៏បានរួមចំណែកយ៉ាងច្រើនក្នុងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការអភិវឌ្ឍសេវានិងឧបករណ៍ទូទាត់ថ្មីៗ ដែលមានកម្រៃទាប និងបង្កើនលទ្ធភាពពង្រីកបណ្តាញផ្តល់សេវាទូទាត់ឱ្យកាន់តែទូលំទូលាយ ដែលអនុញ្ញាតឱ្យប្រជាជននៅតាមទីជនបទចូលរួមប្រើប្រាស់សេវាទូទាត់តាមរយៈបណ្តាញផ្លូវការ។

ដោយសារភាពសំខាន់នៃប្រព័ន្ធទូទាត់ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរផ្នែកប្រព័ន្ធទូទាត់ ដូចមានកំណត់ក្នុងច្បាប់ស្តីពី “ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា” ច្បាប់ស្តីពី “គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ” និងច្បាប់ស្តីពី “ឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់” មានតួនាទីសំខាន់ណាស់ក្នុងការត្រួតពិនិត្យ អភិវឌ្ឍ និងរៀបចំបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធទូទាត់ ដើម្បីធានាបាននូវស្ថិរភាពនិងនិរន្តរភាពនៃដំណើរការប្រព័ន្ធ កាត់បន្ថយហានិភ័យជាប្រព័ន្ធ ការពារផលប្រយោជន៍អតិថិជន និងលើកកម្ពស់ការប្រើប្រាស់ការទូទាត់ជាអេឡិចត្រូនិក។

កន្លងមក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់រាយថ្មីៗ និងកំពុងបន្តអភិវឌ្ឍប្រព័ន្ធទូទាត់រាយដទៃទៀត និងប្រព័ន្ធទូទាត់តម្លៃធំដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅក្នុងសេដ្ឋកិច្ច និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់។ ជាក់ស្តែង ប្រព័ន្ធផាត់ទាត់ជាតិ និងសេវាទូទាត់រហ័សត្រូវបានដាក់ឱ្យដំណើរការ ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់អន្តរធនាគារ។ ប្រព័ន្ធខេមបូខានស៊ែស្វីច និងប្រព័ន្ធរីថែលផេត្រូវបានដាក់ឱ្យដំណើរការបឋម និងគ្រោងដាក់ឱ្យដំណើរការជាផ្លូវការក្នុងពេលឆាប់ៗខាងមុខ។ ប្រព័ន្ធទូទាត់ដុលភ្លាមៗដែលជាប្រព័ន្ធទូទាត់តម្លៃធំក៏កំពុងត្រូវបានអភិវឌ្ឍដើម្បីចូលរួមកាត់បន្ថយហានិភ័យប្រតិបត្តិការ

ទូទាត់តម្លៃធំ ដែលឆ្លើយតបនឹងការរីកចម្រើនបន្តិចម្តងៗនៃទីផ្សារហិរញ្ញវត្ថុ។ ស្របពេលជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងអនុវត្តនូវគម្រោងបាគង សម្រាប់ប្រតិបត្តិការអន្តរធនាគារតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា Blockchain ដើម្បីឆ្លើយតបទៅនឹងការវិវត្តថ្មីៗនៃទម្រង់រូបិយប័ណ្ណ ដែលគម្រោងនេះក៏កំពុងត្រូវបានសិក្សាដោយធនាគារកណ្តាលជាច្រើនក្នុងតំបន់ និងលើពិភពលោក។ ប្រព័ន្ធនេះបានដាក់ឱ្យដំណើរការសាកល្បង កាលពីខែកក្កដា ឆ្នាំ២០១៩ នឹងគ្រោងដាក់ឱ្យដំណើរការផ្លូវការក្នុងពេលឆាប់ៗខាងមុខនេះ។ ទន្ទឹមនោះ ការភ្ជាប់សេវាទូទាត់តាមរយៈ QR កូត រវាងប្រទេសកម្ពុជានិងប្រទេសថៃត្រូវបានដាក់ឱ្យដំណើរការកាលពីខែកុម្ភៈ ឆ្នាំ២០២០ ហើយថ្មីៗនេះ ខេអេចឃ្យូអរកូត (KHQR Code) ដែលជាស្តង់ដារ QR កូត សម្រាប់ប្រទេសកម្ពុជាក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងកំណើននៃការទូទាត់តាមរយៈ QR កូត។

ទន្ទឹមនឹងការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ និងការរីកចម្រើននៃវិស័យទូទាត់ក្នុងទីផ្សារ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ការរៀបចំនូវក្របខណ្ឌបទប្បញ្ញត្តិសមស្របដើម្បីគ្រប់គ្រង និងជំរុញការអភិវឌ្ឍក្នុងវិស័យនេះជាកត្តាចាំបាច់ដើម្បីធានាថា ប្រព័ន្ធទូទាត់បានរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ កន្លងមកធនាគារជាតិនៃកម្ពុជាបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រកាសមួយចំនួន និងកំពុងបន្តរៀបចំប្រកាសបន្ថែមទៀតពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ សេវាទូទាត់ ឧបករណ៍ទូទាត់ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាពប្រព័ន្ធ និងឧបករណ៍ទូទាត់ ព្រមទាំងជំរុញនវានុវត្ត និងការប្រកួតប្រជែងនៃសេវានិងឧបករណ៍ទូទាត់ថ្មីៗក្នុងទីផ្សារ លើកកម្ពស់ការប្រើប្រាស់ស្តង់ដារ និងលទ្ធភាពធ្វើប្រតិបត្តិការឆ្លងគ្នា (Interoperability)។ កត្តាទាំងនេះនឹងរួមចំណែករក្សាជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធទូទាត់ និងកាត់បន្ថយចំណាយប្រតិបត្តិការសម្រាប់ការផ្ទេរប្រាក់ក្នុងប្រទេស និងឆ្លងប្រទេស ព្រមទាំងគាំទ្រដល់គោលនយោបាយលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា។

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងពង្រឹងការអនុវត្តមុខងារត្រួតពិនិត្យរបស់ខ្លួនលើប្រព័ន្ធទូទាត់ និងសេវាទូទាត់តាមរយៈការលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យ ការសិក្សាស្វែងយល់អំពីឧត្តមានុវត្តភាពរបស់ប្រទេសក្នុងតំបន់ និងស្តង់ដារអន្តរជាតិ ដូចជា គោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ការដាក់ឱ្យអនុវត្តក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ និងការរៀបចំនីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ការត្រួតពិនិត្យ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយហានិភ័យប្រព័ន្ធ និងសេវាទូទាត់ទប់ស្កាត់ហានិភ័យជាប្រព័ន្ធ និងពង្រឹងការគោរពតាមក្របខណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ធនាគារជាតិនៃកម្ពុជានឹងបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ ជំរុញការអនុវត្តស្តង់ដារ និងការផ្តល់សេវាប្រកបដោយនវានុវត្ត ព្រមទាំងបន្តរៀបចំក្របខណ្ឌបទប្បញ្ញត្តិសមស្របនិងអនុវត្តការត្រួតពិនិត្យ ដើម្បីបង្កើនលទ្ធភាពធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថាន ពង្រីក

បណ្ដាញផ្ដល់សេវាទូទាត់ឱ្យកាន់តែទូលំទូលាយ ផ្ដល់ភាពងាយស្រួលដល់អតិថិជន និងបង្កបរិយាកាសល្អប្រសើរសម្រាប់ការអភិវឌ្ឍ និងការរីកចម្រើននៃប្រព័ន្ធទូទាត់ប្រកបដោយចីរភាព។

ការសម្រេចបានសមិទ្ធិផលថ្មីៗ ជាពិសេស លើការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់គឺជាលទ្ធផលនៃការរួមចំណែកយ៉ាងសំខាន់របស់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជាដែលបានខិតខំបំពេញការងារយ៉ាងយកចិត្តទុកដាក់ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានាដែលតែងតែផ្ដល់ជំនួយបច្ចេកទេស និងកិច្ចសហការយ៉ាងល្អជាមួយធនាគារ-ជាតិនៃកម្ពុជានារយៈពេលកន្លងមក។ របាយការណ៍នេះ គឺជាឯកសារដ៏មានតម្លៃសម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ និងជាព័ត៌មានដល់ភាគីពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់អំពីកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់ វឌ្ឍនភាព និងបញ្ហាប្រឈម ព្រមទាំងទិសដៅទៅថ្ងៃអនាគត។

# មាតិកា

**អារម្ភកថា** ..... ១

**មាតិកា** ..... ៤

**បញ្ជីតារាង ប្រអប់ និងក្រាហ្វ** ..... ៦

**អក្សរកាត់** ..... ៨

**បរិយាយសង្ខេប** ..... ៩

**១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់** ..... ១២

**១.១. ប្រព័ន្ធទូទាត់សងប្រាក់តម្លៃធំ** ..... ១២

១.១.១. ប្រព័ន្ធទូទាត់ដុលភ្លាមៗ (Real Time Gross Settlement System - RTGS) ..... ១២

១.១.២. ប្រព័ន្ធធនាគារអនឡាញ (Online Banking System - OBS) ..... ១២

**១.២. ប្រព័ន្ធទូទាត់សងប្រាក់រាយ** ..... ១២

១.២.១. ប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System - NCS) ..... ១២

១.២.២. ប្រព័ន្ធទូទាត់រហ័ស (FAST Payment System) ..... ១៦

១.២.៣. ប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch - CSS) ..... ២០

១.២.៤. ប្រព័ន្ធរីថេលផេ (Retail Pay System - RPS) ..... ២៦

**១.៣. ការអភិវឌ្ឍគម្រោងបាគង** ..... ៣១

**១.៤. ការលើកកម្ពស់ការអនុវត្តស្តង់ដារ** ..... ៣៤

**២. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ** ..... ៣៤

**៣. ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់** ..... ៤០

**៣.១. ប្រព័ន្ធទូទាត់សងប្រាក់ដែលមានលក្ខណៈសំខាន់ជាប្រព័ន្ធ (SIPS)** ..... ៤០

**៣.២. ប្រព័ន្ធទូទាត់សងប្រាក់ផ្សេងៗទៀត** ..... ៤៥

៣.២.១. ប្រព័ន្ធទូទាត់រហ័ស (Fast Payment System) ..... ៤៥

៣.២.២. ប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch - CSS) ..... ៤៦

៣.២.៣. ប្រព័ន្ធ Online Banking System (OBS) ........ ៤៧

៣.២.៤. ប្រព័ន្ធរីថែលផេ (Retail Pay) ........ ៤៩

**៣.៣. ការវាយតម្លៃប្រព័ន្ធទូទាត់សងប្រាក់** ........ ៥០

**៤. ប្រតិបត្តិការសេវាទូទាត់សងប្រាក់** ........ ៥១

**៤.១. គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់** ........ ៥១

**៤.២. គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់** ........ ៥២

**៤.៣. ឧបករណ៍ទូទាត់** ........ ៥៣

៤.៣.១. សេវាធនាគារអេឡិចត្រូនិក (E-Banking) ........ ៥៣

៤.៣.២. បណ្ណទូទាត់ និងប្រេកទូទាត់ ........ ៥៤

៤.៣.៣. ការទូទាត់តាម ឃ្យូ អរ កូត (QR Code Payment) ........ ៥៥

**៥. ការផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែន** ........ ៥៥

**៥.១. ប្រតិបត្តិការតាមប្រព័ន្ធស្វីស (SWIFT)** ........ ៥៥

**៥.២. ប្រតិបត្តិការតាមអ្នកដំណើរការតតិយភាគី (Third Party Processor)** ........ ៥៦

**៥.៣. របាយការណ៍ការផ្ទេរប្រាក់ឯកជនឆ្លងដែនតាមប្រព័ន្ធ (ITRS)** ........ ៥៧

**៦. ការសន្និដ្ឋាន និងបញ្ហាប្រឈម** ........ ៥៩

**តារាងឧបសម្ព័ន្ធ១ ៖ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធផាត់ទាត់ជាតិ** ........ ៦១

**តារាងឧបសម្ព័ន្ធ២ ៖ បញ្ជីរាយនាមគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់** ........ ៦២

# បញ្ជីតារាង ប្រអប់ និងក្រាហ្វ

## តារាង


តារាង១ ៖ ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់រៀល ....................................៤២
តារាង២ ៖ ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក .....................៤៣
តារាង៣ ៖ បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ NCS .........................................................៤៤
តារាង៤ ៖ បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ FAST .......................................................៤៥
តារាង៥ ៖ ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS ..............................៤៧
តារាង៦ ៖ ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល តាមប្រព័ន្ធ OBS .....................៤៨
តារាង៧ ៖ ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត តាមប្រព័ន្ធ OBS .....៤៨
តារាង៨ ៖ ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT .........................................៤៩


## ប្រអប់


ប្រអប់១ ៖ ប្រព័ន្ធផាត់ទាត់ជាតិ - ប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ............១៤
ប្រអប់២ ៖ ប្រព័ន្ធផាត់ទាត់ជាតិ - ប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាអេឡិចត្រូនិក .............១៥
ប្រអប់៣ ៖ ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការតាមបញ្ជរគ្រឹះស្ថាន .............................១៧
ប្រអប់៤ ៖ ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការតាមកម្មវិធីទូរស័ព្ទរបស់គ្រឹះស្ថាន ..........១៨
ប្រអប់៥ ៖ ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការផ្ទេរប្រាក់ តាមរយៈម៉ាស៊ីនអេធីអឹម ........១៩
ប្រអប់៦ ៖ ប្រព័ន្ធខេមប៊ូឌានស៊ែស្វីច - ប្រតិបត្តិការដកសាច់ប្រាក់ ....................................២១
ប្រអប់៧ ៖ ប្រព័ន្ធខេមប៊ូឌានស៊ែស្វីច - ប្រតិបត្តិការពិនិត្យសមតុល្យ ................................២២
ប្រអប់៨ ៖ ប្រព័ន្ធខេមប៊ូឌានស៊ែស្វីច - ប្រតិបត្តិការប្តូរលេខសម្ងាត់ ..................................២៣
ប្រអប់៩ ៖ ប្រព័ន្ធខេមប៊ូឌានស៊ែស្វីច - ប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប ................២៤
ប្រអប់១០ ៖ ប្រព័ន្ធខេមប៊ូឌានស៊ែស្វីច - ប្រតិបត្តិការទូទាត់ទំនិញ .....................................២៥
ប្រអប់១១ ៖ ប្រព័ន្ធរីធែលផេ - ប្រតិបត្តិការផ្ទេរប្រាក់នៃ RFT - Real Time Fund Transfer ........២៧
ប្រអប់១២ ៖ ប្រព័ន្ធរីធែលផេ - ប្រតិបត្តិការតាមរយៈ MPS - Mobile Payment System .............២៨
ប្រអប់១៣ ៖ ប្រព័ន្ធរីធែលផេ - ប្រតិបត្តិការនៃប្រព័ន្ធ QPS - QR Code Payment System ...........២៩
ប្រអប់១៤ ៖ ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក-ប្រតិបត្តិការនៃប្រព័ន្ធ ECS – Electronic Clearing System ..៣០
ប្រអប់១៥ ៖ ប្រព័ន្ធបាគង - លក្ខណៈ Backbone ...........................................................៣២
ប្រអប់១៦ ៖ ប្រព័ន្ធបាគង - លក្ខណៈ Extended ..........................................................៣៣
ប្រអប់១៧ ៖ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ .........................................................៥៨

## ក្រាហ្វ


ក្រាហ្វ១ ៖ ចំនួនមូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញ ជាប្រាក់រៀល ................៤២

ក្រាហ្វ២ ៖ ចំនួនមូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញ ជាប្រាក់ដុល្លារអាមេរិក ...៤៣

ក្រាហ្វ៣ ៖ បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក .............៤៤

ក្រាហ្វ៤ ៖ បញ្ជាផ្ទេរឥណទាន និងបញ្ជាផ្ទេរឥណទានបង្វិលវិញ តាមប្រព័ន្ធ FAST ...........៤៦

ក្រាហ្វ៥ ៖ ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធ តាមប្រព័ន្ធ CSS ................................៤៧

ក្រាហ្វ៦ ៖ ការផ្ទេរប្រាក់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក តាមប្រព័ន្ធ OBS ................៤៨

ក្រាហ្វ៧ ៖ ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក តាមប្រព័ន្ធ RFT ........................................................................................................៥០

ក្រាហ្វ៨ ៖ ចំនួនប្រតិបត្តិការនិងទំហំប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់..៥១

ក្រាហ្វ៩ ៖ ចំនួនច្រកទូទាត់ និងអតិថិជនចុះឈ្មោះគណនីកាបូបអេឡិចត្រូនិករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់ ..........................................................៥២

ក្រាហ្វ១០ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ...........៥២

ក្រាហ្វ១១ ៖ ចំនួនច្រកទូទាត់ និងអតិថិជនចុះឈ្មោះគណនីកាបូបអេឡិចត្រូនិករបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ...........................................................................៥៣

ក្រាហ្វ១២ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់របស់សេវាធនាគារអេឡិចត្រូនិក........................៥៣

ក្រាហ្វ១៣ ៖ ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ ........................................................៥៤

ក្រាហ្វ១៤ ៖ ចំនួនម៉ាស៊ីន ATM និង ម៉ាស៊ីនឆូតកាត POS ដែលបានតម្លើង ..........................៥៤

ក្រាហ្វ១៥ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR កូត ........................៥៥

ក្រាហ្វ១៦ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធស្វីស .............៥៦

ក្រាហ្វ១៧ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ តាមរយៈអ្នកដំណើរការតតិយភាគី ........................................................................................................៥៦

ក្រាហ្វ១៨ ៖ ទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឯកជនឆ្លងដែន ចូល/ចេញ ប្រទេសកម្ពុជា ............៥៧

# អក្សរកាត់

| | |
|---|---|
| ACH | Automatic Clearing House |
| ADB | ASEAN Development Bank |
| AI | Artificial Intelligent |
| ATM | Automatic Teller Machine |
| CSS | Cambodian Shared Switch System |
| DNS | Deferred Net Settlement |
| ECS | Electronic Clearing System |
| ITRS | International Transactions Reporting System |
| KHQR Code | Khmer Quick Response Code |
| LPCO | Liquidity Provided Collateralize Operation |
| MPS | Mobile Payment Service |
| NCS | National Clearing System |
| NBC | National Bank of Cambodia |
| NBCP | National Bank of Cambodia Platform |
| NRT | Near Real Time Fund Transfer |
| OBS | Online Banking System |
| POS | Point of Sale |
| PSI | Payment Service Institution |
| RFT | Real Time Fund Transfer |
| RTGS | Real Time Gross Settlement System |
| STP | Straight Through Processing |
| SWIFT | Society for the Worldwide Interbank Financial Telecommunication |
| TPP | Third Party Processor |
| QPS | QR Code Payment System |
| QR Code | Quick Response Code |
| UNCDF | United Nations Capital Development Fund |

# បរិយាយសង្ខេប

បច្ចុប្បន្ន វិស័យធនាគារមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ហើយការផ្តល់សេវាទូទាត់ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេសការទូទាត់ជាអេឡិចត្រូនិក។ ស្ថិតក្នុងបរិបទនេះ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់ដើម្បីជំរុញការប្រើប្រាស់ការទូទាត់ជាអេឡិចត្រូនិក ដែលក្នុងនោះរួមមាន ការកសាងហេដ្ឋារចនា-សម្ព័ន្ធទូទាត់ ការរៀបចំបទប្បញ្ញត្តិ និងការត្រួតពិនិត្យ។

ការកសាង និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធទូទាត់ ជាកត្តាសំខាន់មួយក្នុងការលើកកម្ពស់លទ្ធភាពធ្វើប្រតិបត្តិការឆ្លងគ្នារវាងគ្រឹះស្ថានធនាគារដែលនឹងរួមចំណែកបង្កើនប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ។ នៅខែធ្នូ ឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធផាត់ទាត់ជាតិដែលធ្វើការផាត់ទាត់ និងទូទាត់ប្រតិបត្តិការអន្តរធនាគារតាមរយៈមូលប្បទានបត្រ និងបញ្ជាទូទាត់អេឡិចត្រូនិក មានដូចជា ការផ្ទេរឥណទានឥណទានផ្ទាល់ និងឥណពន្ធផ្ទាល់។ ក្នុងឆមាសទី១ ឆ្នាំ២០២០ ប្រតិបត្តិការមូលប្បទានបត្រមានចំនួន ៦២៥.៤៧៦ ថយចុះ ៥,៩២% និងប្រតិបត្តិការតាមរយៈការផ្ទេរឥណទានមានចំនួន ១៤៤.៥៦៤ កើនឡើង ២៥,៤៧% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។ ទន្ទឹមនោះ នៅខែកក្កដា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័ស ដោយមានការចូលរួមទាំងគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលធ្វើឱ្យបណ្តាញផ្តល់សេវាទូទាត់កាន់តែទូលំទូលាយ និងរួមចំណែកលើកកម្ពស់ការប្រើប្រាស់សេវាទូទាត់តាមបណ្តាញផ្លូវការ។ ការទូទាត់តាមរយៈប្រព័ន្ធសេវាទូទាត់រហ័សក្នុងឆមាសទី១ ឆ្នាំ២០២០ មានចំនួន ២១.៣៦៣ ប្រតិបត្តិការ កើនឡើង ៣៧៣,៦៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។ គួរកត់សម្គាល់ថា ចំនួនប្រតិបត្តិការទូទាត់តាមរយៈសេវាទូទាត់រហ័សមានការកើនឡើងជាលំដាប់ ជាពិសេសក្នុងឆមាសទី១ ឆ្នាំ២០២០ នេះ។ ប្រព័ន្ធ NBC Platform ត្រូវបានដាក់ឱ្យដំណើរការដើម្បីទ្រទ្រង់ដល់ប្រតិបត្តិការជួញដូររូបិយប័ណ្ណ និងមូលបត្ររបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យដំណើរការប្រព័ន្ធ Online Banking System នៅឆ្នាំ២០១៦ និងកំពុងដាក់ឱ្យដំណើរការជាបឋមនូវប្រព័ន្ធខេមបូឌានស៊ែស្វីច និងប្រព័ន្ធរីធែលផេ ហើយក៏កំពុងបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ។ ប្រព័ន្ធបាគងដែលប្រើប្រាស់បច្ចេកវិទ្យា Blockchain ក៏កំពុងដាក់ឱ្យដំណើរការសាកល្បង និងគ្រោងដាក់ឱ្យអតិថិជនប្រើប្រាស់ក្នុងពេលឆាប់ៗនេះ។

បច្ចុប្បន្ននេះ ចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់មានការកើនឡើង និងបានជំរុញឱ្យមានការប្រកួតប្រជែងក្នុងវិស័យនេះយ៉ាងខ្លាំង។ លក្ខណៈនេះគួបផ្សំជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុបានផ្តល់ឱកាសដល់គ្រឹះស្ថានទាំងនេះដាក់ឱ្យប្រើប្រាស់សេវា និង

ឧបករណ៍ទូទាត់ថ្មីៗ ដូចជា ការទូទាត់តាមទូរស័ព្ទចល័ត ការទូទាត់ដោយប្រើប្រាស់ QR កូត ជាដើម ហើយកម្រៃសេវាក៏ធ្លាក់ចុះគួរឱ្យកត់សម្គាល់ផងដែរ។ ទន្ទឹមនេះ ជាមួយនឹងបណ្តាញភ្ជាប់ងារផ្តល់សេវាគ្រប់ទីកន្លែងរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់ បានធ្វើឱ្យការទទួលបានសេវាទូទាត់តាមបណ្តាញផ្លូវការកាន់តែមានភាពងាយស្រួលចំពោះអតិថិជន។

ក្របខណ្ឌគតិយុត្តកំពុងត្រូវបានពង្រឹង តាមរយៈការដាក់ចេញ និងរៀបចំប្រកាសថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍក្នុងវិស័យទូទាត់។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តប្រកាសមួយចំនួនពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ ឧបករណ៍ទូទាត់ និងសេវាទូទាត់ដែលរួមមាន ប្រកាសដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីសម្រាប់ប្រព័ន្ធនីមួយៗ ដែលដំណើរការដោយសភាផាត់ទាត់ជាតិ ប្រកាសស្តីពីមូលប្បទានបត្រស្តង់ដារ ប្រកាសស្តីពីការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន ប្រកាសស្តីពីអ្នកដំណើរការតតិយភាគី ជាដើម។ នៅឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់ ដែលប្រកាសនេះកំណត់ពីនីតិវិធីនៃការស្នើសុំអាជ្ញាបណ្ណចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់ និងកំពុងបន្តរៀបចំប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ បន្ថែមទៀត។ កាលពីខែមករា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងស្តីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់ និងសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ ដើម្បីចូលរួមអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយថ្មីពាក់ព័ន្ធនឹងការកែសម្រួលសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ ជាពិសេសការចូលរួមក្នុងនាមជាសមាជិកមិនផ្ទាល់។ ទន្ទឹមនោះ ដើម្បីលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពក្នុងការទូទាត់តាមរយៈប្រព័ន្ធ CSS ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យអនុវត្តគោលនយោបាយថ្មី ដោយបានកំណត់ពេលវេលាសម្រាប់គ្រឹះស្ថានសមាជិកអនុវត្តស្តង់ដារលេខអត្តសញ្ញាណធនាគារ (Bank Identification Number-BIN) និង Chip EMV លើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ព្រមទាំងគោលការណ៍សុវត្ថិភាពលើម៉ាស៊ីន ATM និង/ឬ POS។ បន្ថែមពីនេះ ស្តង់ដារ Chip Card សម្រាប់ប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ដែលប្រើប្រាស់ក្នុងប្រព័ន្ធ CSS ក៏ត្រូវបានសមាគមធនាគារនៅកម្ពុជាដាក់ឱ្យអនុវត្ត ហើយថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមធនាគារនៅកម្ពុជាបានអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ខេអេចឃ្យូអរកូត (KHQR Code) ដែលជាស្តង់ដារ QR កូត ដើម្បីជំរុញលទ្ធភាពធ្វើប្រតិបត្តិការឆ្លងគ្នានៃសេវាទូទាត់តាមរយៈ QR កូត រវាងគ្រឹះស្ថានផ្តល់សេវាទូទាត់ផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។

ការត្រួតពិនិត្យបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងស្ថិរភាពប្រព័ន្ធទូទាត់នៅកម្ពុជា។ ការត្រួតពិនិត្យត្រូវបានអនុវត្តចំពោះប្រព័ន្ធទូទាត់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់ដែលក្នុងនោះ ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើឡើងតាមរយៈការត្រួតពិនិត្យលើឯកសារ ដោយតម្រូវឱ្យគ្រឹះស្ថានផ្តល់របាយការណ៍ឱ្យបានទៀងទាត់មកធនាគារជាតិនៃកម្ពុជា និងការត្រួតពិនិត្យដល់ទីកន្លែងដែលត្រូវបានអនុវត្តតាមការចាំបាច់។

ដោយឡែក ការត្រួតពិនិត្យប្រព័ន្ធទូទាត់ត្រូវបានអនុវត្តចំពោះប្រព័ន្ធទូទាត់ដំណើរការដោយធនាគារជាតិនៃកម្ពុជា ដែលត្រូវបានចាត់ទុកជាប្រព័ន្ធទូទាត់សំខាន់មានលក្ខណៈជាប្រព័ន្ធ។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យប្រព័ន្ធផាត់ទាត់ជាតិ ធៀបនឹងគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ចំនួន ១៧ ពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ក្នុងចំណោមគោលការណ៍គ្រឹះសរុបចំនួន ២៤។ ទន្ទឹមនោះ ក្របខណ្ឌនៃការត្រួតពិនិត្យប្រព័ន្ធទូទាត់ត្រូវបានដាក់ឱ្យអនុវត្ត និងកំពុងបន្តរៀបចំនីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់ ដើម្បីជាមូលដ្ឋានសម្រាប់ពង្រឹងការត្រួតពិនិត្យឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

ក្នុងក្របខណ្ឌអាស៊ាន ធនាគារជាតិនៃកម្ពុជាជាសមាជិកនៃគណៈកម្មការប្រព័ន្ធទូទាត់អាស៊ាន និងបានចូលរួមរៀបចំ និងអនុវត្តផែនការសកម្មភាពជាយុទ្ធសាស្ត្រក្នុងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ាន ដើម្បីរួមចំណែកទ្រទ្រង់ដល់សហគមសេដ្ឋកិច្ចអាស៊ាន។ កាលពីខែកុម្ភៈ ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានចូលរួមដាក់ឱ្យដំណើរការសេវាទូទាត់ឆ្លងដែនតាមរយៈ QR កូត រវាងប្រទេសកម្ពុជានិងប្រទេសថៃ និងកំពុងសិក្សាពីលទ្ធភាពភ្ជាប់ប្រព័ន្ធទូទាត់ជាមួយបណ្តាប្រទេសសមាជិកអាស៊ានផ្សេងៗទៀតតាមតម្រូវការ និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងការត្រៀមខ្លួនរបស់ប្រទេសកម្ពុជា។

# ១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់

## ១.១. ប្រព័ន្ធទូទាត់សងប្រាក់តម្លៃធំ

### ១.១.១. ប្រព័ន្ធទូទាត់ដុលភ្លាមៗ (Real Time Gross Settlement System - RTGS)

ប្រព័ន្ធទូទាត់ដុលភ្លាមៗ (Real Time Gross Settlement - RTGS) ជាប្រព័ន្ធសម្រាប់ធ្វើការទូទាត់ប្រតិបត្តិការតម្លៃធំ ឬបន្ទាន់មួយប្រតិបត្តិការម្តងៗនិងភ្លាមៗ ដែលភាគច្រើនជាប្រតិបត្តិការនៅក្នុងទីផ្សារអន្តរធនាគារ និងទីផ្សារហិរញ្ញវត្ថុ ហើយប្រព័ន្ធនេះត្រូវបានចាត់ទុកជាហេដ្ឋារចនាសម្ព័ន្ធទូទាត់ដ៏សំខាន់របស់ប្រព័ន្ធទូទាត់ជាតិ។ បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធ RTGS ក្នុងគោលបំណងគាំទ្រការទូទាត់ប្រតិបត្តិការទូទាត់សងប្រាក់ និងផ្ទេរប្រាក់តម្លៃធំអន្តរធនាគារ ប្រតិបត្តិការជួញដូរមូលបត្រ និងជួញដូររូបិយប័ណ្ណ លទ្ធផលផាត់ទាត់សុទ្ធនៃប្រព័ន្ធទូទាត់រាយ ដូចជា ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធខេមបូឌានស៊ែស្វីច ជាដើម។ ការអភិវឌ្ឍប្រព័ន្ធ RTGS ជាផ្នែកមួយនៃការរួមចំណែកធ្វើទំនើបកម្មប្រព័ន្ធទូទាត់ និងលើកកម្ពស់ការប្រើប្រាស់ការទូទាត់ជាអេឡិចត្រូនិក ស្របតាមផែនការសកម្មភាពដែលមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់កម្ពុជា។

### ១.១.២. ប្រព័ន្ធធនាគារអនឡាញ (Online Banking System - OBS)

ប្រព័ន្ធធនាគារអនឡាញ ត្រូវបានដាក់ឱ្យដំណើរការកាលពីខែមករា ឆ្នាំ២០១៦ ក្នុងគោលបំណងកាត់បន្ថយចរាចរណ៍សាច់ប្រាក់ និងសម្រួលនីតិវិធីរដ្ឋបាលក្នុងការរៀបចំឯកសារផ្ទេរមូលនិធិដែលទាមទារនូវពេលវេលាច្រើន និងមានលក្ខណៈស្មុគស្មាញ។ ប្រព័ន្ធ OBS អនុញ្ញាតឱ្យសមាជិកធ្វើប្រតិបត្តិការផ្ទេរប្រាក់ក្នុងទម្រង់ជាបញ្ជាផ្ទេរអេឡិចត្រូនិកតាមអនឡាញ និងពិនិត្យសមតុល្យគណនី (Balance Inquiry)។ បច្ចុប្បន្ន ប្រព័ន្ធនេះមានគ្រឹះស្ថានជាសមាជិក ៥៣ រួមមាន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥២ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ១.២. ប្រព័ន្ធទូទាត់សងប្រាក់រាយ

### ១.២.១. ប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System - NCS)

ដើម្បីជួយសម្រួលដល់គ្រឹះស្ថានធនាគារក្នុងការផាត់ទាត់ និងទូទាត់កាតព្វកិច្ចអន្តរធនាគារ ធនាគារជាតិនៃកម្ពុជាបានបង្កើតសភាផាត់ទាត់ជាតិ និងមណ្ឌលដោះដូរមូលប្បទានបត្ររូបវន្តសម្រាប់សមាជិកនៅឆ្នាំ ១៩៩៤ ដោយមានទីតាំងនៅក្នុងធនាគារជាតិនៃកម្ពុជា។ ជាជំហានបន្ទាប់ ដោយមើលឃើញពីសារៈសំខាន់នៃប្រព័ន្ធទូទាត់រាយ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការធ្វើទំនើបកម្មសភាផាត់ទាត់ជាតិ ដោយចាប់ផ្តើមពីការរៀបចំឱ្យមូលប្បទានបត្រមានលក្ខណៈស្តង់ដារនៅឆ្នាំ២០០៨ និងដាក់ឱ្យប្រើប្រាស់គំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាននៅឆ្នាំ២០១០។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធផាត់ទាត់ជាតិបណ្តោះអាសន្ន (Interim Solution) នៅឆ្នាំ២០០៩ ដើម្បីឱ្យការបញ្ជូន និងការ

ទាញយកទិន្នន័យរវាងសភាផាត់ទាត់ជាតិ និងធនាគារសមាជិកអាចធ្វើបានជាអេឡិចត្រូនិក ដែលមានលក្ខណៈកាន់តែរហ័ស និងមានសុវត្ថិភាពជាងការអនុវត្តពីមុន។ នៅខែធ្នូ ឆ្នាំ២០១២ ប្រព័ន្ធផាត់ទាត់ជាតិត្រូវបានដាក់ឱ្យដំណើរការក្នុងគោលបំណងជួយសម្រួលដល់គ្រឹះស្ថានធនាគារ ក្នុងការផាត់ទាត់និងទូទាត់ប្រតិបត្តិការអន្តរធនាគារ ប្រកបដោយភាពងាយស្រួល និងមានប្រសិទ្ធភាព។ ប្រព័ន្ធនេះអាចធ្វើការផាត់ទាត់ជាលក្ខណៈមជ្ឈការលើមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក ដូចជា ការផ្ទេរឥណទាន ឥណទានផ្ទាល់ ឥណពន្ធផ្ទាល់ ទាំងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក។

កាលពីខែមករា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងអំពីគោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកភាពមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់ និងសមាជិកមិនផ្ទាល់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ ក្នុងគោលបំណងកែសម្រួលនូវគោលនយោបាយមួយចំនួនពាក់ព័ន្ធនឹងការចូលរួមជាសមាជិក ការរៀបចំហេដ្ឋារចនាសម្ព័ន្ធការគ្រប់គ្រង សន្ទនីយភាពសម្រាប់ទូទាត់ ការប្រើប្រាស់លេខកូតសម្គាល់ផ្សេងៗលើឧបករណ៍ទូទាត់ ការប្តូរនិងបញ្ឈប់សមាជិកភាព ការបង់កម្រៃនិងការពិន័យ ការរក្សាការសម្ងាត់ព័ត៌មានអតិថិជនរបស់សមាជិកមិនផ្ទាល់ និងដំណោះស្រាយ។ ជាលទ្ធផលបន្ទាប់ពីចេញសេចក្តីជូនដំណឹងខាងលើ បច្ចុប្បន្ននេះ ប្រព័ន្ធផាត់ទាត់ជាតិមានសមាជិកសរុបចំនួន ៤៧ ដែលក្នុងនោះមាន ៣៣ សមាជិកផ្ទាល់ (ដោយរួមទាំងធនាគារជាតិនៃកម្ពុជាផងដែរ) និង ១៤ សមាជិកមិនផ្ទាល់។ ស្របពេលជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យដំណើរការមណ្ឌលដោះដូរមូលប្បទានបត្រ នៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជាជាបន្តបន្ទាប់ រួមមានសាខា ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តស្វាយរៀង និងខេត្តបន្ទាយមានជ័យ ដើម្បីសម្រួលដល់សមាជិកក្នុងការដោះដូរមូលប្បទានបត្ររូបវន្ត។

ប្រអប់ ១ ៖ ប្រព័ន្ធផាត់ទាត់ជាតិ - ប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ




១. អតិថិជន A បញ្ជូនមូលប្បទានបត្ររបស់អតិថិជន B ដែលមានគណនីនៅធនាគារ B ទៅបញ្ជរធនាគារខ្លួន (ធនាគារ A) ដើម្បីដាក់ប្រាក់ចូលគណនីរបស់ខ្លួន

២. ធនាគារ A ទទួលមូលប្បទានបត្រ និងបញ្ចូលទិន្នន័យរបស់មូលប្បទានបត្រនោះទៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ

៣. ប្រព័ន្ធផាត់ទាត់ជាតិបញ្ជូនទិន្នន័យនៃមូលប្បទានបត្រដែលទទួលបានទៅកាន់ធនាគារទទួល (ធនាគារ B)

៤. មូលប្បទានបត្រនឹងត្រូវបញ្ជូនមកដោះដូរនៅមណ្ឌលដោះដូរមូលប្បទានបត្ររបស់សភាផាត់ទាត់ជាតិ

៥. ធនាគារ B នឹងពិនិត្យសមតុល្យរបស់អតិថិជន B បន្ទាប់ពីទទួលបានទិន្នន័យពីធនាគារ A

៦. ប្រសិនបើអតិថិជន B មានសមតុល្យគ្រប់គ្រាន់ នោះធនាគារ B នឹងដកចំនួនប្រាក់តាមមូលប្បទានបត្រដែលបានទទួលពីគណនីអតិថិជន B ដើម្បីធ្វើការទូទាត់ឱ្យអតិថិជន A ដែលមានគណនីនៅធនាគារ A

៧. ប្រសិនបើគ្មានការបង្វិលវិញនៃមូលប្បទានបត្រ សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារA និងធនាគារ B

៨. ធនាគារ A ចុះឥណទានគណនីអតិថិជន A

៩. ប្រសិនបើអតិថិជន B ពុំមានសមតុល្យគ្រប់គ្រាន់ឬមូលប្បទានបត្រពុំអាចធ្វើការទូទាត់បានដោយមូលហេតុណាមួយក្នុងចំណោមមូលហេតុនៃមូលប្បទានបត្របង្វិលវិញនោះ ធនាគារ B ត្រូវបញ្ជូនមូលប្បទានបត្រនោះ ត្រឡប់ទៅឱ្យធនាគារ A ដើម្បីប្រគល់ឱ្យអតិថិជន A វិញ។

ក្នុងករណីនេះ សភាផាត់ទាត់ត្រូវផាត់ទាត់ (គណនា Net Position) រវាងធនាគារ A និងធនាគារ B ឡើងវិញ សម្រាប់ធ្វើការទូទាត់ ដោយដកចេញមូលប្បទានបត្រដែលមិនអាចទូទាត់បាន។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ២ ៖ ប្រព័ន្ធផាត់ទាត់ជាតិ - ប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាអេឡិចត្រូនិក




១. អតិថិជន A បញ្ជូនបញ្ជាទូទាត់តាមរយៈធនាគាររបស់ខ្លួន (ធនាគារ A) ដើម្បីផ្ទេរប្រាក់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A នឹងពិនិត្យសមតុល្យគណនីនិងភាពត្រឹមត្រូវនៃបញ្ជាទូទាត់របស់អតិថិជន A ប្រសិនបើត្រឹមត្រូវ ធនាគារ A និងដកប្រាក់ពីគណនីអតិថិជន A ដើម្បីត្រៀមទូទាត់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

៣. ធនាគារ A បញ្ចូលទិន្នន័យនៃបញ្ជាទូទាត់នោះទៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ

៤. ប្រព័ន្ធផាត់ទាត់ជាតិនឹងបញ្ជូនទិន្នន័យនៃបញ្ជាទូទាត់ដែលទទួលបានទៅកាន់ធនាគារ B

៥. បន្ទាប់ពីទទួលបានបញ្ជាទូទាត់ពីធនាគារ A ធនាគារ B នឹងពិនិត្យពីភាពត្រឹមត្រូវនៃបញ្ជាទូទាត់នោះ ដើម្បីត្រៀមដាក់ប្រាក់ (ចុះឥណទាន) ក្នុងគណនីអតិថិជន B តាមចំនួនប្រាក់លើបញ្ជាទូទាត់នោះ

៦. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ A និងធនាគារ B

៧. បន្ទាប់ពីការទូទាត់រវាងធនាគារ A និងធនាគារ B បានបញ្ចប់ ធនាគារ B នឹងដាក់ប្រាក់(ចុះឥណទាន) ចូលគណនីអតិថិជន B តាមចំនួនប្រាក់នៃបញ្ជាទូទាត់។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ១.២.២. ប្រព័ន្ធទូទាត់រហ័ស (FAST Payment System)

ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ការបំពេញតម្រូវការសាច់ប្រាក់របស់អតិថិជនបានទាន់ពេលវេលា ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងបរិយាប័ន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធ "សេវាទូទាត់រហ័ស" នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦។ ប្រព័ន្ធ "សេវាទូទាត់រហ័ស" ជាសេវាផ្ទេរមូលនិធិអន្តរធនាគារជាប្រាក់រៀល តាមរយៈគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទូទាំងប្រទេស។ ប្រតិបត្តិការនេះប្រព្រឹត្តទៅបាន តាមរយៈការប្រើប្រាស់ឧបករណ៍ទូទាត់បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក (Credit Remittance) ដោយអតិថិជនអាចផ្ទេរមូលនិធិជាអតិបរមាដល់ ៨០.០០០.០០០ រៀល ហើយអតិថិជនទទួលផលអាចទទួលបានមូលនិធិភ្លាមៗ (Real Time)។ បច្ចុប្បន្ន ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកចំនួន ៥២ គ្រឹះស្ថាន ក្នុងនោះមាន ធនាគារពាណិជ្ជចំនួន ៤៥ ធនាគារឯកទេសចំនួន ១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៦។ ប្រព័ន្ធសេវាទូទាត់រហ័សនឹងផ្តល់ជម្រើសបន្ថែមទៀតសម្រាប់អតិថិជនធ្វើប្រតិបត្តិការទូទាត់ ព្រមទាំងរួមចំណែកឱ្យសកម្មភាពទូទាត់ជាអេឡិចត្រូនិកទាំងក្នុងវិស័យឯកជន និងរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព ឆាប់រហ័ស មានសុវត្ថិភាពដែលនឹងជួយគាំទ្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចថែមទៀត។

ប្រអប់ ៣ ៖ ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការតាមបញ្ជរគ្រឹះស្ថាន




១. អតិថិជន A ទៅកាន់បញ្ជរធនាគាររបស់ខ្លួនគឺធនាគារ A ដើម្បីផ្ទេរប្រាក់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A ពិនិត្យសមតុល្យគណនីរបស់អតិថិជន A ប្រសិនបើមានសមតុល្យគ្រប់គ្រាន់ នោះធនាគារ A នឹងបញ្ចូលទិន្នន័យនៃបញ្ជាផ្ទេរប្រាក់នោះទៅក្នុងប្រព័ន្ធសេវាទូទាត់រហ័ស

៣. ធនាគារ A នឹងកាត់ប្រាក់ (ចុះឥណពន្ធ) ពីគណនីអតិថិជន A ដើម្បីត្រៀមទូទាត់ឱ្យធនាគារ B

៤. ប្រព័ន្ធសេវាទូទាត់រហ័សបញ្ជូនទិន្នន័យនៃបញ្ជាផ្ទេរប្រាក់ដែលទទួលបានទៅកាន់ធនាគារ B

៥. ធនាគារ B នឹងពិនិត្យភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់

៦. ប្រសិនបើព័ត៌មានគ្រប់គ្រាន់និងត្រឹមត្រូវ ធនាគារ B នឹងដាក់ប្រាក់ (ចុះឥណទាន) ចូលគណនីរបស់អតិថិជន B តាមចំនួនប្រាក់នៃបញ្ជាផ្ទេរប្រាក់នោះ

៧. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ A និងធនាគារ B។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ៤ ៖ ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការតាមកម្មវិធីទូរស័ព្ទរបស់គ្រឹះស្ថាន




១. អតិថិជន A ត្រូវពិនិត្យសមតុល្យគណនីរបស់ខ្លួន មុនពេលបញ្ជូនបញ្ជាផ្ទេរប្រាក់តាមរយៈកម្មវិធីទូរស័ព្ទរបស់ធនាគារខ្លួន (ធនាគារ A) ដើម្បីផ្ទេរប្រាក់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A ពិនិត្យភាពត្រឹមត្រូវរបស់ទិន្នន័យនៃបញ្ជាផ្ទេរប្រាក់ដែលបានបញ្ចូលទៅក្នុងកម្មវិធីទូរស័ព្ទនោះ

៣. បន្ទាប់ពីពិនិត្យមើលភាពត្រឹមត្រូវនៃព័ត៌មានលើបញ្ជាផ្ទេរប្រាក់ និងភាពគ្រប់គ្រាន់នៃសមតុល្យ ធនាគារ A នឹងបញ្ជូនទិន្នន័យនោះទៅកាន់ប្រព័ន្ធសេវាទូទាត់រហ័ស

៤. ធនាគារ A នឹងកាត់ប្រាក់ (ចុះឥណពន្ធ) ពីគណនីរបស់អតិថិជន A ដើម្បីត្រៀមទូទាត់ទៅឱ្យធនាគារ B

៥. ប្រព័ន្ធសេវាទូទាត់រហ័សនឹងបញ្ជូនទិន្នន័យនៃបញ្ជាផ្ទេរប្រាក់ដែលទទួលបានពីធនាគារ A ទៅកាន់ធនាគារ B

៦. ធនាគារ B នឹងពិនិត្យភាពត្រឹមត្រូវលើបញ្ជាផ្ទេរប្រាក់

៧. ប្រសិនបើព័ត៌មានគ្រប់គ្រាន់និងត្រឹមត្រូវ ធនាគារ B នឹងដាក់ប្រាក់ (ចុះឥណទាន) ចូលគណនីរបស់អតិថិជន B តាមចំនួនប្រាក់នៃបញ្ជាផ្ទេរប្រាក់នោះ

៨. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ A និងធនាគារ B។

សម្គាល់៖ ករណីនេះសម្រាប់តែគ្រឹះស្ថានសមាជិកដែលបានភ្ជាប់សេវាធនាគារចល័ត ឬសេវាធនាគារអ៊ីនធើណែតជាមួយប្រព័ន្ធសេវាទូទាត់រហ័សប៉ុណ្ណោះ។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ៥ ៖ ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការផ្ទេរប្រាក់ តាមរយៈម៉ាស៊ីនអេធីអឹម




១. អតិថិជន A បញ្ចូលប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ រួចវាយ PIN និងជ្រើសរើសប្រភេទប្រតិបត្តិការផ្ទេរប្រាក់ បន្ទាប់មកបញ្ចូលចំនួនប្រាក់ដែលត្រូវផ្ទេរទៅឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ Beneficiary

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់នោះ រួចបញ្ជូនទៅកាន់ប្រព័ន្ធសេវាទូទាត់រហ័ស

៣. ប្រព័ន្ធសេវាទូទាត់រហ័ស នឹងបញ្ជូនបញ្ជាផ្ទេរប្រាក់ដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ដោយបញ្ជូនការបញ្ជាក់នោះទៅកាន់ធនាគារ ACQ តាមរយៈប្រព័ន្ធសេវាទូទាត់រហ័ស

៥. ស្របពេលជាមួយគ្នានេះ ប្រព័ន្ធសេវាទូទាត់រហ័ស នឹងបញ្ជូនDeposit advice messageទៅធនាគារ Beneficiary

៦. ធនាគារ ACQ អនុញ្ញាតឱ្យអតិថិជន A ផ្ទេរប្រាក់ដោយជោគជ័យ បន្ទាប់មកម៉ាស៊ីន ATM បោះផ្សាយវិក្កយបត្រសម្រាប់អតិថិជន

៧. ធនាគារ IS S នឹងដកប្រាក់ចេញពីគណនីអតិថិជន A

៨. ធនាគារ Beneficiary នឹងដាក់ប្រាក់ចូលទៅក្នុងគណនីរបស់អតិថិជន B តាមចំនួនប្រាក់នៃបញ្ជាផ្ទេរប្រាក់

៩. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ ACQ , ធនាគារ ISS និងធនាគារ Beneficiary។

សម្គាល់៖ - ធនាគារ ISS សំដៅលើសមាជិកដែលមានគណនីអ្នកកាន់ប័ណ្ណ និងចេញផ្សាយប័ណ្ណទៅឱ្យអ្នកកាន់ប័ណ្ណ។

- ធនាគារ ACQ សំដៅលើសមាជិកជាម្ចាស់ ATM ឬ POS។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ១.២.៣. ប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch - CSS)

កន្លងមក ការទូទាត់សងប្រាក់ដោយប្រើប្រាស់ប័ណ្ណទូទាត់ពុំទាន់ផ្តល់ប្រសិទ្ធភាព និងភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់នៅឡើយទេ ព្រោះអតិថិជនមិនអាចប្រើប្រាស់ប័ណ្ណរបស់ខ្លួនជាមួយម៉ាស៊ីន ATM ឬ POS របស់ធនាគារដទៃទៀត និងមិនអាចទូទាត់សងប្រាក់ជាលក្ខណៈអន្តរធនាគារ។ ដើម្បីដោះស្រាយបញ្ហានេះ និងឆ្លើយតបទៅនឹងការអភិវឌ្ឍនាពេលបច្ចុប្បន្ន ក៏ដូចជាអនុវត្តឱ្យស្របទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាបឋម (Soft Launch) នូវប្រព័ន្ធ CSS នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ដោយមានគ្រឹះស្ថានស្ថាបនិកចំនួន ៣ បានចូលរួម។ ប្រព័ន្ធនេះបានបំពេញមុខងារផាត់ទាត់លើប្រតិបត្តិការអន្តរធនាគារ ដែលធ្វើឡើងតាមរយៈប័ណ្ណទូទាត់ឥណពន្ធលើម៉ាស៊ីន ATM និង POS (ប័ណ្ណទូទាត់ណាក៏អាចប្រើបានជាមួយម៉ាស៊ីន ATM និង POS របស់បណ្តាគ្រឹះស្ថានជាសមាជិក)។ បច្ចុប្បន្ន គ្រឹះស្ថានសមាជិកប្រព័ន្ធ CSS មានចំនួន ៥១ ក្នុងនោះរួមមាន ធនាគារពាណិជ្ជ ៤៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៦ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១ ហើយគ្រឹះស្ថានដែលបានដាក់ឱ្យដំណើរការបឋមមានចំនួន ២៧។

ប្រព័ន្ធ CSS ដំណើរការជារៀងរាល់ថ្ងៃ (២៤/៧) ហើយអតិថិជនរបស់គ្រឹះស្ថានជាសមាជិកអាចធ្វើប្រតិបត្តិការប័ណ្ណឥណពន្ធរបស់ខ្លួននៅគ្រប់ម៉ាស៊ីន ATM និង POS ដែលមានស្លាកសញ្ញា CSS។ ចំពោះសេវាតាមរយៈម៉ាស៊ីន ATM អតិថិជនអាចធ្វើប្រតិបត្តិការដកសាច់ប្រាក់ ពិនិត្យសមតុល្យ របាយការណ៍សង្ខេប ផ្ទេរប្រាក់ (ប្រាក់រៀលតែប៉ុណ្ណោះ) និងប្តូរលេខសម្ងាត់ ខណៈពេលដែលអតិថិជនអាចធ្វើប្រតិបត្តិការទិញ ពិនិត្យសមតុល្យ ដកសាច់ប្រាក់តាមរយៈម៉ាស៊ីន POS។ ដោយឡែក សម្រាប់ប្រភេទប័ណ្ណ Co-badge របស់ក្រុមហ៊ុនប័ណ្ណទូទាត់អន្តរជាតិ (ដូចជា Visa, MasterCard, UnionPay ជាដើម) អតិថិជនអាចជ្រើសរើសកិច្ចដំណើរការប្រតិបត្តិការរបស់ខ្លួន តាមរយៈបណ្តាញប្រព័ន្ធខេមបូឌានស៊ែស្វីច ឬប័ណ្ណទូទាត់អន្តរជាតិ។

ដើម្បីលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពក្នុងការទូទាត់តាមរយៈប្រព័ន្ធ CSS ធនាគារ-ជាតិនៃកម្ពុជាបាន ដាក់ចេញសេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធ CSS ដោយកំណត់ពេលវេលាតម្រូវឱ្យគ្រឹះស្ថានសមាជិកអនុវត្តស្តង់ដារលេខអត្តសញ្ញាណធនាគារ (Bank Identification Number-BIN) និង Chip EMV លើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ព្រមទាំងគោលការណ៍សុវត្ថិភាពលើម៉ាស៊ីន ATM និង/ឬ POS និងសេចក្តីជូនដំណឹងស្តីពី គោលនយោបាយពាក់ព័ន្ធនឹងសមាជិកភាពប្រព័ន្ធ CSS។

ប្រព័ន្ធនេះគ្រោងដាក់ឱ្យដំណើរការជាផ្លូវការនាពេលឆាប់ៗខាងមុខនេះ។ ការដាក់ឱ្យដំណើរការប្រព័ន្ធនេះនឹងក្លាយជាកត្តាមួយជំរុញការទូទាត់រាយជាអេឡិចត្រូនិក កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់ តាមរយៈការកាត់បន្ថយការវិនិយោគលើម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងផ្តល់ភាពងាយស្រួលក្នុងការទូទាត់ទំនិញនិងសេវា។

ប្រអប់ ៦ ៖ ប្រព័ន្ធខេមប៊ូខានស៊ែស្វិច - ប្រតិបត្តិការដកសាច់ប្រាក់




១. អតិថិជន A បញ្ចូលបណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM /POS របស់ធនាគារ ACQ រួចវាយ PIN និងជ្រើសរើសប្រភេទប្រតិបត្តិការដកប្រាក់ បន្ទាប់មកត្រូវវាយចំនួនប្រាក់ដែលត្រូវដក

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃបញ្ជាដកប្រាក់នោះ រួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនបញ្ជាដកប្រាក់ដែលទទួលបានពីធនាគារ ACQ ទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ រួចបញ្ជូនការបញ្ជាក់ពីភាពត្រឹមត្រូវទៅកាន់ធនាគារ ACQ វិញតាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ISS នឹងដកប្រាក់ពីគណនីរបស់អតិថិជន A តាមចំនួនប្រាក់នៃបញ្ជាដកប្រាក់

៦. ធនាគារ ACQ អនុញ្ញាតឱ្យអតិថិជន A ដកប្រាក់

៧. ម៉ាស៊ីន ATM/POS បោះផ្សាយវិក្កយបត្រសម្រាប់អតិថិជន

៨. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការរវាងធនាគារ ACQ និងធនាគារ ISS។

សម្គាល់៖ - ធនាគារ ISS សំដៅលើសមាជិកដែលមានគណនីអ្នកកាន់បណ្ណ និងចេញផ្សាយប័ណ្ណទៅឱ្យអ្នកកាន់បណ្ណ។

- ធនាគារ ACQ សំដៅលើសមាជិកជាម្ចាស់ ATM ឬ POS។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់ ៧ ៖ ប្រព័ន្ធខេមប៊ូខានស៊ែស្វីច - ប្រតិបត្តិការពិនិត្យសមតុល្យ**




១. អតិថិជន A ស៊កប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ បន្ទាប់មកបញ្ចូល PIN រួចជ្រើសរើសយកប្រតិបត្តិការពិនិត្យសមតុល្យគណនី

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃសំណើពិនិត្យសមតុល្យ រួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនសំណើពិនិត្យសមតុល្យដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជូនព័ត៌មានសមតុល្យគណនីរបស់អតិថិជន A មកធនាគារ ACQ តាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ACQ នឹងបង្ហាញព័ត៌មានលម្អិតនៃសមតុល្យគណនីនោះ នៅលើអេក្រង់ម៉ាស៊ីន ATM។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ៨ ៖ ប្រព័ន្ធខេមប៊ិុខានស៊ែស្វីច - ប្រតិបត្តិការប្តូរលេខសម្ងាត់




១. អតិថិជន A ស៊កបញ្ចូលប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ បន្ទាប់មកបញ្ចូល PIN រួចជ្រើសរើសយកប្រតិបត្តិការប្តូរលេខសម្ងាត់

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃសំណើសុំប្តូរលេខសម្ងាត់ រួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនសំណើសុំប្តូរលេខសម្ងាត់ដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃសំណើសុំប្តូរលេខសម្ងាត់ រួចបញ្ជូនការបញ្ជាក់នោះ មកកាន់ធនាគារ ACQ តាមរយៈប្រព័ន្ធ CSS តាមជំហាននីមួយៗ

៥. អតិថិជនត្រូវធ្វើតាមការណែនាំដែលមាននៅលើអេក្រង់ម៉ាស៊ីន ATM ដើម្បីផ្លាស់ប្តូរលេខសម្ងាត់។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ៩ ៖ ប្រព័ន្ធខេមប៊ិខានស៊ែស្វីច - ប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប




១. អតិថិជន A ស៊កប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ បន្ទាប់មកបញ្ចូល PIN រួចជ្រើសរើសយកប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃសំណើសុំពិនិត្យរបាយការណ៍សង្ខេបរួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនសំណើសុំពិនិត្យរបាយការណ៍សង្ខេបដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជូនរបាយការណ៍សង្ខេបនោះទៅកាន់ធនាគារ ACQ វិញតាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ACQ នឹងបង្ហាញរបាយការណ៍សង្ខេបនោះលើអេក្រង់ម៉ាស៊ីន ATM បន្ទាប់មកម៉ាស៊ីន ATM បោះផ្សាយរបាយការណ៍សង្ខេបសម្រាប់អតិថិជន A។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ១០ ៖ ប្រព័ន្ធខេមប៊ូឌានស៊ែស្វីច - ប្រតិបត្តិការទូទាត់ទំនិញ




១. ភ្នាក់ងារអាជីវកម្ម (Merchant) ស៊កប័ណ្ណទូទាត់របស់អតិថិជនទៅក្នុងម៉ាស៊ីន POS របស់ខ្លួន បន្ទាប់មកបញ្ចូលចំនួនប្រាក់ដែលអតិថិជន A ត្រូវទូទាត់និងស្នើសុំឱ្យអតិថិជនបញ្ចូល PIN រួចបញ្ជូនមកធនាគារ ACQ

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃបញ្ជាទូទាត់នោះរួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនទិន្នន័យនៃបញ្ជាទូទាត់ដែលទទួលបានពីធនាគារ ACQ ទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃបញ្ជាទូទាត់នោះ រួចបញ្ជូនការបញ្ជាក់ពីភាពត្រឹមត្រូវនោះទៅកាន់ធនាគារ ACQ វិញ តាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ACQ អនុញ្ញាតឱ្យអតិថិជន A ធ្វើការទូទាត់

៦. ធនាគារ ISS នឹងដកប្រាក់ពីគណនីរបស់អតិថិជន A តាមចំនួនប្រាក់នៃបញ្ជាទូទាត់ដើម្បីត្រៀមទូទាត់ឱ្យ Merchant ដែលមានគណនីនៅធនាគារ ACQ

៧. ម៉ាស៊ីន POS នឹងបោះផ្សាយវិក្កយប័ត្រប្រតិបត្តិការនោះសម្រាប់អតិថិជន

៨. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ ISS និងធនាគារ ACQ

៩. ធនាគារ ACQ នឹងដាក់ប្រាក់ (ចុះឥណទាន) ក្នុងគណនីរបស់ Merchant នៅថ្ងៃបន្ទាប់។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ១.២.៤. ប្រព័ន្ធរីថែលផេ (Retail Pay System - RPS)

ធនាគារជាតិនៃកម្ពុជាបានទទួលជំនួយពីរដ្ឋាភិបាលកូរ៉េ តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) លើគម្រោងអភិវឌ្ឍប្រព័ន្ធទូទាត់វាយ "រីថែលផេ" ដោយមានប្រព័ន្ធរងចំនួន ៤ រួមមាន (១) ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (Real Time Fund Transfer-RFT) (២) ប្រព័ន្ធទូទាត់ចល័ត (Mobile Payment Service-MPS) (៣) ប្រព័ន្ធ QPS (QR Code Payment System) និង (៤) ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក (Electronic Clearing System-ECS)។ ប្រព័ន្ធ RFT ជាប្រព័ន្ធផ្ទេរមូលនិធិដែលអតិថិជនអាចទទួលបានមូលនិធិភ្លាម តាមរយៈការផ្ទេរពីគណនីទៅគណនី និងពីគណនីទៅលេខទូរស័ព្ទ។ លក្ខណៈពិសេសនៃប្រព័ន្ធនេះ គឺអ្នកផ្ញើអាចទទួលបានសារ ដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់អំពីព័ត៌មានរបស់អ្នកទទួលផលមុនពេលមូលនិធិត្រូវបានផ្ទេរទៅក្នុងគណនី។ ជាមួយនឹងការប្រើប្រាស់ប្រព័ន្ធនេះ អតិថិជនអាចផ្ទេរមូលនិធិជាអតិបរមាចំនួន ២០០ លានរៀល តាមរយៈការផ្ទេរពីគណនីទៅគណនី និងតិចជាង ៤ លានរៀល តាមរយៈការផ្ទេរពីគណនីទៅលេខទូរស័ព្ទ ហើយអាចដំណើរការបាន ២៤/៧។ ប្រព័ន្ធ MPS ជាកម្មវិធីធនាគារចល័តរួម (Common Mobile Banking App) ដែលអតិថិជនអាចទាញយកមកប្រើប្រាស់តាមរយៈកម្មវិធី Android និង IOS Version។ ប្រព័ន្ធ MPS មានមុខងារជាច្រកសម្រាប់ការផ្ទេរប្រាក់ក្នុងធនាគារ ផ្ទេរប្រាក់អន្តរធនាគារ និងធ្វើប្រតិបត្តិការធនាគារចល័តផ្សេងទៀត។ ប្រព័ន្ធ QPS ជាប្រព័ន្ធទូទាត់ចល័ត (Mobile App) តាមរយៈការស្កេន QR កូដ ដែលផ្តល់មុខងារដូចជា ការទិញ/ការលក់ ការដកសាច់ប្រាក់តាមភ្នាក់ងារពាណិជ្ជករ ការពិនិត្យសមតុល្យ និងការបញ្ជូនមូលនិធិត្រឡប់វិញ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ គម្រោងនេះមានគ្រឹះស្ថានជាសមាជិកចំនួន ២០ ដែលរួមមានធនាគារពាណិជ្ជចំនួន ១៥ និងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៥ ក្នុងនោះមាន ២០ គ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធ RFT ១២ គ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធ MPS និង ១៤ គ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធ QPS។ ជាមួយគ្នានេះដែរ ប្រព័ន្ធរីថែលផេ បានដាក់ឱ្យដំណើរការជាបឋមកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ដោយមានកិច្ចសហការពីគ្រឹះស្ថានស្ថាបនិកចំនួន ៨ ហើយប្រព័ន្ធនេះគ្រោងនឹងដាក់ឱ្យដំណើរការជាផ្លូវការនាពេលឆាប់ៗខាងមុខ។

**ប្រអប់ ១១ ៖ ប្រព័ន្ធរីថៃលផេ - ប្រតិបត្តិការផ្ទេរប្រាក់នៃ RFT - Real Time Fund Transfer**




១. អតិថិជន A ទៅកាន់ធនាគាររបស់ខ្លួន (ធនាគារ A) ដើម្បីផ្ទេរប្រាក់ទៅកាន់អតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A នឹងពិនិត្យមើល ភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ នឹងកាត់ចំនួនប្រាក់ដែលត្រូវផ្ទេរ (ចុះឥណពន្ធ) ពីគណនីអតិថិជន A រួចបញ្ជូនបញ្ជាផ្ទេរប្រាក់ទៅកាន់ប្រព័ន្ធ Retail Pay

៣. ប្រព័ន្ធ Retail Pay នឹងបញ្ជូនបញ្ជាផ្ទេរប្រាក់ដែលទទួលបានទៅកាន់ធនាគារ B

៤. ធនាគារ B នឹងពិនិត្យមើលពីភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ ប្រសិនបើត្រឹមត្រូវ ធនាគារ B នឹងដាក់ប្រាក់ (ចុះឥណទាន) ចូលក្នុងគណនីរបស់អតិថិជន B ភ្លាមៗ

៥. ធនាគារ B នឹងបញ្ជាក់ពីភាពជោគជ័យនៃប្រតិបត្តិការទៅធនាគារ A វិញតាមប្រព័ន្ធ RFT

៦. Electronic Clearing System (ECS) នៃប្រព័ន្ធរីថៃលផេ នឹងផាត់ទាត់ប្រតិបត្តិការទាំងនោះ បន្ទាប់មកបញ្ជូនលទ្ធផលផាត់ទាត់សរុបទៅកាន់ប្រព័ន្ធ Core Banking ដើម្បីទូទាត់

<u>សម្គាល់</u> ៖ តាមរយៈការប្រើប្រាស់ប្រព័ន្ធ RFT អតិថិជនអាចផ្ទេរប្រាក់បាន ១)ពីគណនីទៅគណនី និង ២)ពីគណនីទៅលេខទូរស័ព្ទ។ ករណីនៃការផ្ទេរប្រាក់ពីគណនីទៅលេខទូរស័ព្ទ អតិថិជនទទួលត្រូវបង្ហាញអត្តសញ្ញាណរបស់ខ្លួន លេខទូរស័ព្ទរបស់ខ្លួន លេខទូរស័ព្ទអ្នកផ្ញើ និងលេខសម្គាល់ OTP ដែលទទួលបានពីអតិថិជនផ្ញើ នៅពេលទៅដកប្រាក់ នៅតាមគ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធ RFT ណាមួយ។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់ ១២ ៖ ប្រព័ន្ធរីថៃលផេ - ប្រតិបត្តិការតាមរយៈ MPS - Mobile Payment System**




១. អតិថិជន A ធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមកម្មវិធីទូរស័ព្ទចល័តរបស់ធនាគារខ្លួន (ធនាគារ A) ដើម្បីផ្ទេរប្រាក់ទៅកាន់អតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A នឹងពិនិត្យមើលភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ដែលមាននៅលើកម្មវិធីទូរស័ព្ទនោះ រួចបញ្ជូនទៅកាន់ប្រព័ន្ធ Retail Pay

៣. ធនាគារ A នឹងកាត់ប្រាក់ (ចុះឥណពន្ធ) ពីគណនីរបស់អតិថិជន A ដើម្បីត្រៀមទូទាត់ទៅឱ្យអតិថិជន B

៤. ប្រព័ន្ធ Retail Pay នឹងបញ្ជូនបញ្ជាផ្ទេរប្រាក់ដែលទទួលបានទៅកាន់ធនាគារ B

៥. ធនាគារ B នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មាន ប្រសិនបើត្រឹមត្រូវ ធនាគារ B នឹងដាក់ប្រាក់ (ចុះឥណទាន) ទៅក្នុងគណនីរបស់អតិថិជន B តាមចំនួនប្រាក់នៃបញ្ជាផ្ទេរប្រាក់ភ្លាមៗ

៦. ធនាគារ B នឹងបញ្ជាក់ពីភាពជោគជ័យនៃប្រតិបត្តិការទៅធនាគារ A និងអតិថិជន A វិញ តាមប្រព័ន្ធ RFT

៧. Electronic Clearing System (ECS) នៃប្រព័ន្ធរីថៃលផេ នឹងផាត់ទាត់ប្រតិបត្តិការទាំងនោះ បន្ទាប់មកបញ្ជូនលទ្ធផលផាត់ទាត់សរុបទៅកាន់ប្រព័ន្ធ Core Banking ដើម្បីទូទាត់

<u>សម្គាល់</u> ៖ អតិថិជនអាចធ្វើប្រតិបត្តិការតាមរយៈប្រព័ន្ធ MPS ឬ កម្មវិធីទូរស័ព្ទរបស់ធនាគារដែលជាសមាជិកប្រព័ន្ធ Retail Pay ចំពោះតែគ្រឹះស្ថានដែលបានធ្វើសន្ទានកម្មប្រព័ន្ធ នៅលើកម្មវិធីទូរស័ព្ទរបស់ខ្លួនប៉ុណ្ណោះ។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ១៣ ៖ ប្រព័ន្ធរីថែលផេ - ប្រតិបត្តិការនៃប្រព័ន្ធ QPS - QR Code Payment System




១. នៅពេលទូទាត់ទំនិញ ឬសេវា អតិថិជន A ត្រូវស្កេន QR កូត របស់ភ្នាក់ងាររអាជីវកម្ម តាមរយៈ Customer Mobile App បន្ទាប់មកព័ត៌មានរបស់អតិថិជននឹងត្រូវបញ្ជូនទៅកាន់ ISS Processor

២. ISS Processor ក៏បញ្ជូនព័ត៌មាននោះទៅកាន់ធនាគារ ISS ដើម្បីពិនិត្យពីភាពត្រឹមត្រូវ និងសមតុល្យគណនីរបស់អតិថិជន

៣. ISS Processor នឹងបញ្ជូនបន្តនូវព័ត៌មាននោះទៅកាន់ប្រព័ន្ធ Retail Pay ដើម្បីផ្ទៀងផ្ទាត់ជាមួយ Tokenize Message

៤. ប្រសិនបើការផ្ទៀងផ្ទាត់ត្រឹមត្រូវ ប្រព័ន្ធRetail Pay នឹងបញ្ជាក់ថាការទូទាត់បានជោគជ័យ រួចផ្ញើ Acknowledge message ទៅកាន់ ISS Processor និង ACQ Processor

៥. បន្ទាប់ពីទទួលបាន Acknowledge message ពីប្រព័ន្ធ Retail Pay នោះ ISS Processor និង ACQ Processor នឹងបញ្ជូនសារនៃប្រតិបត្តិការជោគជ័យបន្តទៅកាន់ធនាគារ ISS និងធនាគារ ACQ

៦. ធនាគារ ISS នឹងចុះឥណពន្ធសមតុល្យគណនីអតិថិជន A ហើយចេញផ្សាយនូវវិក័យប័ត្រនៃការទូទាត់ទំនិញអោយអតិថិជន A

៧. ភ្នាក់ងាររអាជីវកម្មអាចពិនិត្យចំនួនប្រាក់ដែលទទួលបាននៅក្នុង Merchant Mobile App របស់ខ្លួនភ្លាមៗ ប៉ុន្តែនឹងទទួលបានប្រាក់បន្ទាប់ពីសភាផាត់ទាត់បញ្ចប់ការផាត់ទាត់និងទូទាត់រវាងធនាគារ ISS និងធនាគារ ACQ នៅថ្ងៃបន្ទាប់(T+1)។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ១៤ ៖ ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក - ប្រតិបត្តិការនៃប្រព័ន្ធ ECS – Electronic Clearing System




១. ប្រព័ន្ធ RFT និងប្រព័ន្ធ QPS នឹងបញ្ជូនទិន្នន័យប្រតិបត្តិការរបស់ខ្លួនមកកាន់ Electronic Clearing System-ECS នៃប្រព័ន្ធរីថេលផេ ដើម្បីធ្វើការផាត់ទាត់រួម

២. Electronic Clearing System (ECS) នៃប្រព័ន្ធរីថេលផេ នឹងផាត់ទាត់ប្រតិបត្តិការទាំងនោះ បន្ទាប់មកបញ្ជូននូវលទ្ធផលផាត់ទាត់សរុប ទៅកាន់ប្រព័ន្ធ Core banking ដើម្បីធ្វើការទូទាត់

៣. Electronic Clearing System (ECS) នៃប្រព័ន្ធរីថេលផេ នឹងបញ្ជូនរបាយការណ៍លទ្ធផលនៃការទូទាត់ដែលទទួលបានពីប្រព័ន្ធ Core banking ទៅកាន់ធនាគារផ្ញើ/ACQ និង ធនាគារទទួល/ISS។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ១.៣. ការអភិវឌ្ឍគម្រោងបាគង

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍគម្រោងបាគង ដែលជាផ្នែកមួយក្នុងការចូលរួមធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់រាយ ក្នុងគោលដៅលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ គោលបំណងនៃការអភិវឌ្ឍប្រព័ន្ធនេះ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនសេដ្ឋកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន ដោយក្នុងនោះរួមមាន (១) លើកកម្ពស់អន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ដែលអតិថិជនចុងក្រោយជាអ្នកទទួលអត្ថប្រយោជន៍ (២) កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ក្នុងទីផ្សារ តម្លៃសេវាថោក និងលុបបំបាត់ហានិភ័យនៃការកាន់សាច់ប្រាក់ និង (៣) ចូលរួមលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុដែលអតិថិជនអាចទទួលបានសេវាគ្រប់ទីកន្លែងជាអេឡិចត្រូនិក(២៤/៧)។ គម្រោង “បាគង” នេះ ត្រូវបានប្រើប្រាស់ដោយបច្ចេកវិទ្យា Blockchain និងគោរពតាមគោលការណ៍ដែលអាចកំណត់សម្គាល់អត្តសញ្ញាណរបស់អតិថិជន (Know Your Customer, KYC) បានយ៉ាងច្បាស់លាស់ និងត្រឹមត្រូវ។ បច្ចេកវិទ្យានេះមានសមត្ថភាពខ្ពស់ក្នុងការការពារពីការលួចវាយប្រហារពីជនអនាមិក (Hacker) ចូលទៅក្នុងប្រព័ន្ធ។ លើសពីនេះ បច្ចេកវិទ្យា Blockchain មានសមត្ថភាពអាចតាមដាន កត់ត្រា និងគ្រប់គ្រងលើគណនីនីមួយៗបានយ៉ាងមានប្រសិទ្ធភាពផងដែរ។ ប្រព័ន្ធបាគងមានលក្ខណៈចំនួនពីរផ្សេងគ្នា គឺលក្ខណៈ Backbone (Backbone Feature) និងលក្ខណៈ Extended (Extended Feature)។ លក្ខណៈ Backbone សំដៅលើប្រតិបត្តិការទូទាត់អន្តរគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយគ្រឹះស្ថានជាសមាជិកត្រូវបង្កើតគណនីបាគងនៅធនាគារជាតិនៃកម្ពុជាសម្រាប់គ្រឹះស្ថានខ្លួន ដើម្បីធ្វើប្រតិបត្តិការទូទាត់ដែលមានក្នុងប្រព័ន្ធបាគង ហើយទំហំប្រាក់ប្រតិបត្តិការក្នុងប្រព័ន្ធនេះមិនមានកំណត់ឡើយ។ ចំពោះលក្ខណៈ Extended សំដៅលើប្រតិបត្តិការទូទាត់អន្តរគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយគ្រឹះស្ថានជាសមាជិកត្រូវបង្កើតគណនីបាគងសម្រាប់អតិថិជនរបស់ខ្លួន និងអាចធ្វើប្រតិបត្តិការតាមរយៈកម្មវិធីសេវាទូរស័ព្ទចល័តបាគងរបស់ធនាគារជាតិនៃកម្ពុជា (NBC’s Bakong Generic App) ឬតាមរយៈកម្មវិធីសេវាទូរស័ព្ទចល័តរបស់គ្រឹះស្ថានសមាជិក។ ជាមួយនឹងលក្ខណៈ Extended នេះ ទំហំប្រាក់រក្សាក្នុងគណនីបាគង (Bakong wallet stored) អតិបរមាបានចំនួន ១០ លានរៀល ឬ ២.៥០០ ដុល្លារអាមេរិក។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ចំនួន ១៤ បានចូលរួមដាក់ឲ្យដំណើរការសាកល្បងប្រព័ន្ធបាគង និង ២៥ គ្រឹះស្ថានផ្សេងទៀត ទទួលបានគោលការណ៍អនុញ្ញាតចូលជាសមាជិកក្នុងប្រព័ន្ធបាគង ហើយប្រព័ន្ធនេះគ្រោងនឹងដាក់ឱ្យដំណើរការជាផ្លូវការនៅក្នុងឆ្នាំ២០២០ នេះផងដែរ។

ប្រអប់ ១៥ ៖ ប្រព័ន្ធបាគង - លក្ខណៈ **Backbone**




- អ្នកផ្ញើរ បញ្ជូនបញ្ជាផ្ញើរទៅធនាគារអ្នកផ្ញើរ (ឧ. តាមបញ្ជរធនាគារ ឬធនាគារអេឡិចត្រូនិក)
- ធនាគារអ្នកផ្ញើរ ពិនិត្យអត្តសញ្ញាណរបស់អ្នកផ្ញើរ និងចំនួនមូលនិធិនៅក្នុងគណនីធនាគារ
- ធនាគារអ្នកផ្ញើរ នឹងបញ្ជូនបញ្ជាផ្ញើរទៅប្រព័ន្ធបាគង ប្រសិនគណនីរបស់អ្នកផ្ញើរមានមូលនិធិគ្រប់គ្រាន់

- បញ្ជាផ្ញើរត្រូវបានទទួល និងផ្ទៀងផ្ទាត់
- ប្រតិបត្តិការត្រូវបានទូទាត់

- មូលនិធិ ត្រូវបានផ្ញើរចូលក្នុងគណនីធនាគាររបស់អ្នកទទួល
- ផ្ទៀងផ្ទាត់ព័ត៌មាន ក្នុងចំណោម Nodes
- ធនាគារអ្នកផ្ញើរ និងធនាគារអ្នកទទួល នឹងទទួលបានព័ត៌មានអំពី ប្រតិបត្តិការទូទាត់ជោគជ័យ

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រអប់ ១៦ ៖ ប្រព័ន្ធបាគង - លក្ខណៈ Extended




- អ្នកផ្ញើរ បញ្ជូនបញ្ជាផ្ញើរតាម BAKONG App
- ធនាគារអ្នកផ្ញើរ ពិនិត្យអត្តសញ្ញាណរបស់អ្នកផ្ញើរ និងចំនួនមូលនិធិនៅក្នុងគណនីធនាគារ
- ធនាគារអ្នកផ្ញើរ នឹងបញ្ជូនបញ្ជាផ្ញើរ និងព័ត៌មានទៅប្រព័ន្ធបាគង ប្រសិនមូលនិធិរបស់អ្នកផ្ញើរមានគ្រប់គ្រាន់

- បញ្ជាផ្ញើរត្រូវបានទទួល និងផ្ទៀងផ្ទាត់
- ប្រតិបត្តិការត្រូវបានទូទាត់

- មូលនិធិ ត្រូវបានផ្ញើរចូលគណនីបាគងរបស់អ្នកទទួល
- ធនាគារអ្នកផ្ញើរ និងធនាគារអ្នកទទួល នឹងទទួលបានព័ត៌មានអំពីប្រតិបត្តិការទូទាត់ជោគជ័យ

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ១.៤. ការលើកកម្ពស់ការអនុវត្តស្តង់ដារ

ការប្រើប្រាស់ស្តង់ដាររួមបានរួមចំណែកក្នុងការលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពក្នុងការទូទាត់តាមរយៈការផ្តល់ការការពារខ្ពស់ដល់អតិថិជនពីការលួចបន្លំផ្សេងៗ និងអាចឱ្យអតិថិជនធ្វើប្រតិបត្តិការឆ្លងគ្នាបាន។ មិនតែប៉ុណ្ណោះ ការអនុវត្តស្តង់ដាររួមដែលស្របនឹងស្តង់ដារអន្តរជាតិ ជាកត្តាមួយដែលផ្តល់លទ្ធភាពខ្ពស់ ក្នុងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់ផងដែរ។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រកាសស្តីពីមូលប្បទានបត្រស្តង់ដារនិងគំរូបញ្ជាផ្ទេរឥណទានអេឡិចត្រូនិកដែលកំណត់ពីលក្ខណៈស្តង់ដារមូលប្បទានបត្រនិងបញ្ជាផ្ទេរឥណទាន សម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធធនាគារ។ ដើម្បីលើកកម្ពស់សុវត្ថិភាពនិងលទ្ធភាពធ្វើប្រតិបត្តិការឆ្លងរវាងប័ណ្ណទូទាត់ឥណពន្ធរបស់គ្រឹះស្ថានសមាជិកសមាគមធនាគារនៅកម្ពុជាបានដាក់ឱ្យប្រើប្រាស់ស្តង់ដារ EMV Chip Card សម្រាប់ប្រព័ន្ធ CSS។ ទន្ទឹមនោះ ខេអេចឃ្យូអរកូត (KHQR Code) ដែលជាស្តង់ដារ QR កូត របស់ប្រទេសកម្ពុជាត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីខែមិថុនា ឆ្នាំ២០២០ ដើម្បីសម្រួលការទូទាត់ឆ្លងគ្រឹះស្ថានតាមរយៈ QR កូត។

## ២. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ

កម្រងច្បាប់សំខាន់ៗដែលបានអនុម័ត និងកំពុងរៀបចំដោយធនាគារជាតិនៃកម្ពុជា គឺធ្វើឡើងក្នុងគោលបំណងធានាសុវត្ថិភាព និងប្រសិទ្ធភាពប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជា ដោយជំរុញការប្រកួតប្រជែងរវាងគ្រឹះស្ថានដែលជាភាគីចូលរួមប្រកបដោយតម្លាភាព លើកកម្ពស់ការទូទាត់មិនប្រើសាច់ប្រាក់ ប្រតិបត្តិការអន្តរធនាគារ និងជាពិសេសជំរុញបរិយាប័ន្នហិរញ្ញវត្ថុ រួមទាំងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗដែលប្រើប្រាស់សម្រាប់ប្រព័ន្ធទូទាត់សងប្រាក់នៅព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម៖

- **ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារនៃកម្ពុជា (១៩៩៦)៖** កំណត់ពីមុខងារនិងភារៈកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ដែលអនុញ្ញាតឱ្យធនាគារកណ្តាលដើរតួនាទីជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធទូទាត់សងប្រាក់នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញមុខងារបីសំខាន់ៗ រួមមាន៖ (១)ជាប្រតិបត្តិករប្រព័ន្ធទូទាត់សងប្រាក់ (២)ជាអ្នកសម្របសម្រួល និងជំរុញការអភិវឌ្ឍប្រព័ន្ធ និងសេវាទូទាត់សងប្រាក់ និង (៣)ជាបញ្ញត្តិករ ឬអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់។
- **ច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ (១៩៩៧)៖** អនុវត្តចំពោះប្រតិបត្តិការនៃរូបិយប័ណ្ណដែលមានចរន្តចេញចូលក្នុងប្រទេសដែលកើតឡើងដោយនិវាសជន និងអនិវាសជនពាក់ព័ន្ធទៅនឹងការទូទាត់ពាណិជ្ជកម្ម ការផ្ទេរប្រាក់ និងចលនានៃដើមទុនដោយរួមបញ្ចូលទាំងការវិនិយោគ។

- **ច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (១៩៩៩)៖** កំណត់អំពីមុខងារ កាតព្វកិច្ច និងប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានទទួលអាជ្ញាបណ្ណពីធនាគារ-ជាតិនៃកម្ពុជា ដើម្បីដំណើរការសេវាធនាគាររួមមាន ការទទួលប្រាក់បញ្ញើ ការផ្តល់ឥណទាន និងការផ្តល់មធ្យោបាយទូទាត់សងប្រាក់។
- **ច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ (២០០៥)៖** ផ្តល់សិទ្ធិអំណាចគតិយុត្តឱ្យធនាគារជាតិនៃកម្ពុជា គ្រប់គ្រងលើឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ដែលរួមបញ្ចូលទាំងគណនីធនាគារ និងប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់។
- **ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (២០២០)៖** ដាក់ចេញវិធានការសម្រាប់បុគ្គលរាយការណ៍ឱ្យអនុវត្តតាម ដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងរៀបចំចាត់ចែង និងត្រួតពិនិត្យការប្រតិបត្តិតាមវិធាន។

ក្រៅពីក្របខណ្ឌច្បាប់ធំៗ ដែលបានដាក់ចេញកន្លងមក ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំដាក់ចេញនូវបទប្បញ្ញត្តិផ្សេងៗជាច្រើនទៀត ដែលអនុលោមតាមច្បាប់ដោយមានលក្ខណៈរឹងមាំ លម្អិត និងល្អប្រសើរ ហើយបទប្បញ្ញត្តិទាំងនោះរួមមាន៖

- **ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ (២០០៦) ៖** កំណត់ពីយន្តការ ឬនីតិវិធីសម្រាប់ធនាគារជាតិនៃកម្ពុជាអនុវត្ត ក្នុងការទប់ស្កាត់ហានិភ័យដែលអាចកើតមានឡើងមកលើប្រព័ន្ធទូទាត់សងប្រាក់សំខាន់មានលក្ខណៈជាប្រព័ន្ធឱ្យស្ថិតនៅកម្រិតទាបបំផុតដែលអាចទទួលយកបាន។
- **ប្រកាសស្តីពី ប្រតិបត្តិការនៃគណនីទូទាត់ (២០០៦)៖** កំណត់ពីលក្ខខណ្ឌ និងកាតព្វកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅក្នុងស្រុក ហើយគ្រឹះស្ថាននោះមានបំណងផ្តល់សេវាបញ្ជាទូទាត់អន្តរធនាគារឱ្យចូលជាសមាជិកនៃសភាផាត់-ទាត់ជាតិ និងបើកគណនីទូទាត់នៅធនាគារជាតិនៃកម្ពុជា។
- **ប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ (២០០៨) ៖** កំណត់ឱ្យមាននូវការឯកភាពជាលក្ខណៈស្តង់ដារមូលប្បទានបត្រដែលប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារដើម្បីឱ្យការទូទាត់ និងផាត់ទាត់អន្តរធនាគារប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព។
- **ប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ(២០០៨)៖**កំណត់លេខអត្តសញ្ញាណសម្រាប់សម្គាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីចារឹកលេខកូតរបស់ធនាគារនៅលើមូលប្បទានបត្រដែលអាចអានបានដោយម៉ាស៊ីនស្របតាមមូលប្បទានបត្រស្តង់ដារ។
- **ប្រកាសស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន (២០១០) ៖** ដាក់ឱ្យប្រើឯកភាពគ្នានៅក្នុងប្រព័ន្ធធនាគារនូវគំរូបញ្ជាទូទាត់សម្រាប់ការទូទាត់សងប្រាក់ជាលាយលក្ខណ៍អក្សរ ឬអេឡិចត្រូនិកដែលមានទម្រង់ជាការផ្ទេរឥណទាន។

- **ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី (២០១០)** ៖ ផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដើម្បីប្រគល់មួយផ្នែក ឬច្រើនផ្នែកនៃសេវាទូទាត់សងប្រាក់ឱ្យអ្នកដំណើរការតតិយភាគីមួយ ឬច្រើន ដូចបានព្រមព្រៀងគ្នារវាងធនាគារ និងអ្នកដំណើរការតតិយភាគីទាំងនោះ និងដែលត្រូវមានការអនុញ្ញាតជាមុនស្របតាមមាត្រា ២០៤ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់។
- **ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ (២០១៤)** ៖ ផ្តល់លទ្ធភាពដល់សមាជិកសភាផាត់ទាត់ជាតិ ទទួលបានសន្ទនីយភាពពីធនាគារជាតិនៃកម្ពុជា ក្នុងរូបភាពជា "ឥណទានវិបារូបន៍" ដើម្បីសម្រួលដល់កង្វះសន្ទនីយភាពចាំបាច់សម្រាប់បំពេញកាតព្វកិច្ចទូទាត់ក្នុងថ្ងៃ។ ការផ្តល់ឥណទានវិបារូបន៍មានគោលដៅធានាការទូទាត់ក្នុងថ្ងៃឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់។
- **ប្រកាសស្តីពី សមាជិកភាពនៃប្រព័ន្ធ FAST System និង Central Shared Switch (២០១៦)** ៖ តម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចូលរួមជាសមាជិកនៃប្រព័ន្ធ FAST System និង Central Shared Switch ជាកាតព្វកិច្ច ដើម្បីជំរុញការទូទាត់រាយឱ្យមានលក្ខណៈកាន់តែងាយស្រួល រហ័ស ប្រសិទ្ធភាព សុវត្ថិភាព និងជឿទុកចិត្តបានក្នុងទិសដៅលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ជំរុញបរិយាប័ន្នហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិ។
- **ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ (២០១៦)** ៖ ផ្តល់ជាមូលដ្ឋានក្នុងការអនុវត្តចំពោះប្រព័ន្ធ National Clearing System និង FAST System ដែលធានាប្រតិបត្តិការទូទាត់សងប្រាក់ឱ្យរលូន និងការគ្រប់គ្រងរបស់សភាផាត់ទាត់ជាតិឱ្យមានប្រសិទ្ធភាព។ វិធាន និងនីតិវិធីនេះ មានគោលបំណងគ្រប់គ្រងប្រតិបត្តិការរបស់សភាផាត់ទាត់ជាតិ និងសម្រាប់សមាជិកអនុវត្តតាម ក្នុងការចេញផ្សាយទទួលយក និង/ឬ ដំណើរការមូលប្បទានបត្រ និងឧបករណ៍បញ្ជាទូទាត់សងប្រាក់ នៅក្នុងដំណើរការផាត់ទាត់ និងទូទាត់ឧបករណ៍ទូទាត់សងប្រាក់ រួមទាំងយន្តការដោះស្រាយបញ្ហាផ្សេងៗពាក់ព័ន្ធនឹងឧបករណ៍ទាំងនោះ។ វិធាន និងនីតិវិធីនេះ ក៏បម្រើដល់កិច្ចដំណើរការ និងការគ្រប់គ្រងសភាផាត់ទាត់ជាតិឱ្យប្រព្រឹត្តិទៅដោយរលូន និងជាចំណងផ្លូវច្បាប់ចំពោះគ្រប់សមាជិកសភាផាត់ទាត់ជាតិ។
- **ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធី Cambodian Shared Switch (២០១៧)** ៖ ផ្តល់ជាមូលដ្ឋាននៃការអនុវត្តការផាត់ទាត់ និងទូទាត់តាមរយៈប្រព័ន្ធ CSS ដែលបម្រើដល់កិច្ចដំណើរការ និងការគ្រប់គ្រងប្រព័ន្ធ CSS នៃធនាគារជាតិនៃកម្ពុជា។
- **ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ (២០១៧)** ៖ កំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណរបស់នីតិបុគ្គលដែលមានបំណងផ្តល់សេវាទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ បន្ថែមលើនេះ ប្រកាសនេះត្រូវបានអនុញ្ញាតក្នុងគោលបំណងធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់

ជំរុញការប្រកួតប្រជែងឱ្យមានតម្លាភាព និងលើកកម្ពស់គំនិតច្នៃប្រឌិត ព្រមទាំងផ្តល់ទំនុកចិត្តដល់សាធារណជនមកលើសេវាទូទាត់សងប្រាក់។

- **ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (FAST Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) (២០១៨) ៖** កំណត់ពីស្លាកសញ្ញារបស់ប្រព័ន្ធទូទាត់រហ័ស និងប្រព័ន្ធខេមបូឌានស៊ែស្វីច ជាផ្លូវការសម្រាប់ប្រើប្រាស់នៅក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលដៅរក្សាសង្គតិភាពក្នុងការប្រើប្រាស់ជាសាធារណៈ ព្រមទាំងធានាអំពីសិទ្ធិ និងកាតព្វកិច្ចក្នុងការប្រើប្រាស់ប្រព័ន្ធ និងការពារផលប្រយោជន៍របស់គ្រឹះស្ថានជាសមាជិក។
- **ប្រកាសស្តីពី ការដាក់ឲ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ Retail Pay (២០១៩) ៖** កំណត់ស្លាកសញ្ញារបស់ប្រព័ន្ធ Retail Pay សម្រាប់ជាសញ្ញាសម្គាល់ផ្លូវការប្រើប្រាស់ក្នុងប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ។
- **ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Retail Pay (២០២០) ៖** ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារ "វិធាននិងនីតិវិធី Retail Pay" ដែលរួមមានប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ ប្រព័ន្ធទូទាត់ចល័ត ប្រព័ន្ធទូទាត់តាមរយៈ QR កូត និងប្រព័ន្ធផាត់ទាត់អេឡិចត្រូនិកជាមូលដ្ឋានកំណត់ពីកិច្ចដំណើរការរបស់ប្រព័ន្ធ និងកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានដែលជាសមាជិក ដើម្បីជំរុញការទូទាត់ជាអេឡិចត្រូនិកឱ្យប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។
- **ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេអេចយូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ (២០២០) ៖** ប្រកាសនេះ មានគោលបំណងដាក់ឱ្យប្រើប្រាស់ឯកសារស្តីពី គំរូបរិច្ឆិនភាពបច្ចេកទេស (Specification) ខ្មែរឃ្វីករ៉េសស្ប៉ុនកូត (KHMER QUICK RESPONSE CODE) ហៅកាត់ថា ខេអេចយូអរកូត "KHQR Code" សម្រាប់ការទូទាត់សងប្រាក់នៅព្រះរាជាណាចក្រកម្ពុជា។
- **ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង (២០២០) ៖** ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង ដែលជាឯកសារគតិយុត្តសម្រាប់អនុវត្តក្នុងការធ្វើប្រតិបត្តិការប្រព័ន្ធបាគង។
- **ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង (២០២០) ៖** ប្រកាសនេះមានគោលបំណងកំណត់ស្លាកសញ្ញារបស់ប្រព័ន្ធទូទាត់ "បាគង" តទៅនេះហៅថា ប្រព័ន្ធបាគង សម្រាប់ជាសញ្ញាសម្គាល់ដើម្បីប្រើប្រាស់នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ និងក្នុងការធ្វើប្រតិបត្តិការប្រព័ន្ធបាគង ហើយអនុញ្ញាតឱ្យគ្រឹះស្ថានជាសមាជិកប្រព័ន្ធប្រើសម្រាប់អនុវត្តការងារពាក់ព័ន្ធ។

- **ក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ (២០២០)៖** រៀបចំឡើងជាឯកសារមូលដ្ឋានសម្រាប់កំណត់អំពីនីតិវិធី និងវិសាលភាពច្បាស់លាស់សម្រាប់យកមកធ្វើជាកម្រិតគោល (Benchmark) ដើម្បីយកមកវិភាគ និងវាយតម្លៃអំពីកម្រិតហានិភ័យចម្បងៗរបស់ប្រព័ន្ធទូទាត់សងប្រាក់។
- **សារាចរណែនាំស្តីពី ការពង្រឹងការអនុវត្តច្បាប់ឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់ (២០១៦)៖** អនុវត្តច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ឱ្យបានម៉ឺងម៉ាត់និងពេញលេញ ធានាបាននូវប្រសិទ្ធភាពនៃការទូទាត់ បង្កើនភាពជឿជាក់លើឧបករណ៍ទូទាត់ ការពារផលប្រយោជន៍អ្នកទទួលផល ព្រមទាំងដើម្បីកាត់បន្ថយបរិមាណមូលប្បទានបត្របង្វិលវិញ។
- **សេចក្តីជូនដំណឹងស្តីពី កម្រៃ សោហ៊ុយ និងការពិន័យសម្រាប់ប្រព័ន្ធខេមបូឌាន-ស៊ែស្វីច (២០១៧)៖** ការកំណត់អំពីកម្រៃ សោហ៊ុយ និងការពិន័យផ្សេងៗនៃប្រព័ន្ធខេមបូឌានស៊ែស្វីច។
- **សេចក្តីជូនដំណឹងស្តីពី ការកែសម្រួលគោលនយោបាយសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System) របស់សភាផាត់ទាត់ជាតិ (២០១៨)៖** កំណត់ពីការកែសម្រួលគោលនយោបាយសមាជិកភាពរបស់ប្រព័ន្ធផាត់ទាត់ជាតិ។
- **សេចក្តីជូនដំណឹងស្តីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់និងសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ (២០១៩)៖** កំណត់អំពីគោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់និងកិច្ចសហការរវាងសមាជិកផ្ទាល់និងសមាជិកមិនផ្ទាល់។
- **សេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូឌានស៊ែស្វីច៖** ដើម្បីសម្រួលឱ្យការទូទាត់វាយធ្វើឡើងកាន់តែមានភាពងាយស្រួល រហ័ស សុវត្ថិភាព និងអាចទុកចិត្តបាន ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល។
- **សេចក្តីជូនដំណឹងស្តីពី គោលនយោបាយពាក់ព័ន្ធនឹងសមាជិកភាពប្រព័ន្ធខេមបូឌាន-ស៊ែស្វីច៖** ដើម្បីពង្រឹងការអនុវត្តស្តង់ដារលេខអត្តសញ្ញាណធនាគារ (Bank Identification Number - BIN) និង Chip EMV លើប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ព្រមទាំងគោលការណ៍សុវត្ថិភាពលើម៉ាស៊ីន ATM និង/ឬ POS និងការធ្វើសន្ទានកម្មប្រព័ន្ធ។
- **សេចក្តីណែនាំស្តីពី កាលបរិច្ឆេទ និងរយៈពេលសម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៖** សេចក្តីណែនាំនេះរៀបរាប់អំពីកាតព្វកិច្ចធ្វើរបាយការណ៍ដូចជា ព័ត៌មានចាំបាច់មួយចំនួនតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា និងកំណត់ពីកាលបរិច្ឆេទសម្រាប់របាយការណ៍។

- **សេចក្ដីណែនាំស្ដីពី ការជ្រើសរើស និងការទទួលស្គាល់ស្នងការគណនេយ្យឯករាជ្យចំពោះគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ ៖** សេចក្ដីណែនាំនេះតម្រូវឱ្យគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ត្រូវជ្រើសរើស និងស្នើសុំការទទួលស្គាល់ស្នងការគណនេយ្យឯករាជ្យ សម្រាប់ធ្វើរបាយការណ៍សវនកម្មប្រចាំឆ្នាំ និងផ្ញើរបាយការណ៍នេះមកធនាគារជាតិនៃកម្ពុជាឱ្យបានទៀងទាត់។

លើសពីនេះ ពេលបច្ចុប្បន្ន ដោយសារការរីកចម្រើនឥតឈប់ឈរនៃវិស័យបច្ចេកវិទ្យា បានធ្វើឱ្យសេវាទូទាត់ និងឧបករណ៍ទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជាមានការអភិវឌ្ឍរីកចម្រើនជាបន្តបន្ទាប់ ជាពិសេសការផ្លាស់ប្ដូររបៀបធ្វើការ គំរូពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុកំណើនប្រតិបត្តិការ និងសេវាហិរញ្ញវត្ថុថ្មីៗដែលតម្រូវឱ្យមានក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិរឹងមាំ និងសង្គតិភាព ដើម្បីធានានូវសុវត្ថិភាព និងប្រសិទ្ធភាពសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់ ក៏ដូចជាពង្រឹងជំនឿសាធារណជនមកលើប្រព័ន្ធទូទាត់ និងប្រព័ន្ធធនាគារនៅកម្ពុជា។ ដូចនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិបន្ថែមទៀត ដើម្បីបន្តជំរុញវិស័យទូទាត់សងប្រាក់ សំដៅលើកកម្ពស់ការប្រកួតប្រជែងដោយមានតម្លាភាព ប្រសិទ្ធភាព និងបរិយាប័ន្នហិរញ្ញវត្ថុ ដែលបង្កភាពអំណោយផលដល់គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ឱ្យសម្រេចបានស្ថិរភាពថ្លៃ និងស្ថិរភាពហិរញ្ញវត្ថុ សំដៅជំរុញកំណើនសេដ្ឋកិច្ច។ តាមរយៈនេះ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលធនាគារជាតិនៃកម្ពុជាកំពុងរៀបចំសម្រាប់ទិសដៅទៅថ្ងៃខាងមុខ រួមមាន៖

### ក)- បទប្បញ្ញត្តិសម្រាប់ប្រព័ន្ធទូទាត់សងប្រាក់

- **ប្រកាសស្ដីពី ប្រតិបត្តិការ និងការគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ ៖** កំណត់ពីលក្ខខណ្ឌ និងនីតិវិធីក្នុងការស្នើសុំអាជ្ញាបណ្ណជាប្រតិបត្តិករទូទាត់សងប្រាក់ ក៏ដូចជាកំណត់អំពីសិទ្ធិរបស់ធនាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ ដែលតម្រូវឱ្យប្រតិបត្តិករគោរព និងអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នដូចមានចែងនៅក្នុងប្រកាសនេះ។ ប្រកាសនេះ មានគោលបំណងធានាសុវត្ថិភាព និងប្រសិទ្ធភាពប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីលើកកម្ពស់ និងជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធធនាគារ។
- **ប្រកាសស្ដីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីប្រព័ន្ធទូទាត់ដុលភ្លាមៗ៖** ជាមូលដ្ឋានសម្រាប់កំណត់ពីកិច្ចដំណើរការប្រព័ន្ធ ក៏ដូចជាកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានដែលជាសមាជិក ក្នុងគោលដៅធានាសុវត្ថិភាព និងប្រសិទ្ធភាពនៃប្រព័ន្ធទូទាត់ដុលភ្លាមៗ។

### ខ)- បទប្បញ្ញត្តិសម្រាប់សេវាទូទាត់សងប្រាក់

- **ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៖** កំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដើម្បីធានាអំពីភាពរឹងមាំ សុវត្ថិភាព និងភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថាន ដើម្បីផ្តល់ជំនឿទុកចិត្តដល់សាធារណជន និងជំរុញសេវាទូទាត់សងប្រាក់នៅប្រទេសកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយស្ថិរភាព។
- **ប្រកាសស្តីពី ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៖** កំណត់ពីលក្ខខណ្ឌ និងនីតិវិធីសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្នើសុំការអនុញ្ញាតក្នុងការជ្រើសរើសភ្នាក់ងារ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុដែលមានកម្រិតក្នុងនាមធនាគារ ក្នុងទិសដៅសម្រេចឱ្យបានបរិយាប័ន្នហិរញ្ញវត្ថុ ធានាសុវត្ថិភាព និងប្រសិទ្ធភាព និងលើកកម្ពស់ការប្រកួតប្រជែងដោយស្មោះត្រង់ និងតម្លាភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។
- **ប្រកាសស្តីពី ការគ្រប់គ្រងគណនីអាណត្តិព្យាបាល ៖** កំណត់ពីគោលការណ៍សម្រាប់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ធ្វើការធានាភាពគ្រប់គ្រាន់ និងសុវត្ថិភាពនៃគណនីអាណត្តិព្យាបាល ក្នុងគោលបំណងការពារផលប្រយោជន៍អតិថិជនដែលប្រើប្រាស់សេវាទូទាត់សងប្រាក់។
- **សេចក្តីណែនាំស្តីពី ការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៖** ជានីតិវិធីត្រួតពិនិត្យដែលបានចងក្រងសម្រាប់មន្ត្រីទទួលបន្ទុកសិក្សា និងស្វែងយល់ក្នុងការអនុវត្តកាតព្វកិច្ចត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ប្រកបដោយប្រសិទ្ធភាព និងជំនាញច្បាស់លាស់។

## ៣. ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់

ការគ្រប់គ្រង និងតាមដានហានិភ័យប្រព័ន្ធទូទាត់សងប្រាក់ អនុវត្តឡើងក្នុងគោលបំណងស្វែងយល់ពីបញ្ហាប្រឈមនានា និងគ្រប់គ្រងលើហានិភ័យដែលអាចនឹងកើតមានឡើងចំពោះប្រព័ន្ធទូទាត់សងប្រាក់។ ដូច្នេះ ដើម្បីធានាបាននូវកិច្ចដំណើរការរបស់ប្រព័ន្ធទូទាត់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងធានាបាននូវភាពរឹងមាំនៃប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានតាមដាន និងត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាជាប្រចាំ។ ប្រព័ន្ធទូទាត់សងប្រាក់ ដែលស្ថិតនៅក្រោមកម្មវត្ថុក្នុងការតាមដាន និងត្រួតពិនិត្យដោយធនាគារជាតិនៃកម្ពុជា មានដូចខាងក្រោម៖

### ៣.១. ប្រព័ន្ធទូទាត់សងប្រាក់ដែលមានលក្ខណៈសំខាន់ជាប្រព័ន្ធ (SIPS)

ប្រព័ន្ធទូទាត់សងប្រាក់ដែលមានលក្ខណៈសំខាន់ជាប្រព័ន្ធជាហេដ្ឋារចនាសម្ព័ន្ធដែលទ្រទ្រង់ប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់សងប្រាក់អន្តរធនាគារដែលមានតម្លៃធំ។ នាពេលបច្ចុប្បន្ន បើពិនិត្យទៅលើទំហំនិងបរិមាណរបស់ប្រតិបត្តិការ ប្រព័ន្ធផាត់ទាត់ជាតិរបស់ធនាគារ-

ជាតិនៃកម្ពុជាដែលប្រតិបត្តិដោយសភាផាត់ទាត់ជាតិ ត្រូវចាត់ទុកជាប្រព័ន្ធដែលមានលក្ខណៈសំខាន់ (SIPS)។ ឧបករណ៍ទូទាត់សងប្រាក់ដែលបានប្រើប្រាស់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ រួមមានមូលប្បទានបត្រ (Checks) និងបញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក (Electronic Payment Orders)។

ក្នុងឆមាសទី១ ឆ្នាំ២០២០ នេះ ការទូទាត់មូលប្បទានបត្រ និងបញ្ជាផ្ទេរឥណទានបានដំណើរការចំនួន ១២២ថ្ងៃ ហើយក្នុងអំឡុងពេលប្រតិបត្តិការ ប្រព័ន្ធផាត់ទាត់ជាតិបានជួបបញ្ហាមួយចំនួនដូចជា រអាក់រអួលផ្នែកបច្ចេកទេសខ្លះៗ ក្នុងការដំណើរការផាត់ទាត់ ដែលបណ្តាលមកពីដាច់បណ្តាញ Network (ប្រព័ន្ធមិនអាចទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយប្រព័ន្ធធនាគារស្នូលបាន)។ បញ្ហានេះត្រូវបានដោះស្រាយភ្លាមៗ ដើម្បីធានាបាននូវភាពរឹងមាំនៃការទូទាត់ប្រកបដោយមានប្រសិទ្ធភាព។ ដោយឡែក ចំពោះការពន្យារពេលទូទាត់ដោយមូលហេតុបច្ចេកទេស ឬកង្វះសន្ទនីយភាព គឺសមាជិកនីមួយៗបានយកចិត្តទុកដាក់ក្នុងការពិនិត្យតាមដានសមតុល្យនៅក្នុងគណនីទូទាត់ ដើម្បីធានាថាមានមូលនិធិគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចទូទាត់នៅក្នុងថ្ងៃ។

ជារួម ប្រព័ន្ធផាត់ទាត់ជាតិបានដំណើរការដោយរលូន ដែលបច្ចុប្បន្នប្រព័ន្ធនេះអាចរក្សាបាននូវការអនុវត្តសម្រេចបានកម្រិតស្តង់ដារបច្ចេកទេស ៩៥% (កៅសិបប្រាំភាគរយ) នៃរង្វាស់គោល ១០០% (មួយរយភាគរយ)។ ការអនុវត្តប្រចាំថ្ងៃត្រូវបានគណនាដោយធៀបនឹងកម្រិតគោលសម្រាប់ដំណើរការប្រចាំថ្ងៃដូចជា ពេលវេលាផាត់ទាត់ និងទូទាត់ជាក់ស្តែង (៨០%) ពេលវេលាចាប់ផ្តើមជាក់ស្តែងក្នុងថ្ងៃ (៥%) ម៉ោងឈប់ទទួល Input (៥%) ពេលវេលាទូទាត់ជាក់ស្តែង (៥%) ព្រមទាំងបញ្ហាផ្សេងៗនៃកិច្ចដំណើរការជាក់ស្តែងដែលកើតឡើងដោយសារការធ្វើបច្ចុប្បន្នកម្ម និងការផ្លាស់ប្តូរកម្មវិធី (៥%)។ ក្នុងគោលដៅជំរុញការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិឱ្យស្របទៅនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់ក្នុងតំបន់ និងបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការផាត់ទាត់ ធនាគារជាតិនៃកម្ពុជាកំពុងធ្វើទំនើបកម្មប្រព័ន្ធផាត់ទាត់ជាតិឱ្យទៅជាប្រព័ន្ធដែលមានការទូទាត់សុទ្ធតាមកាលគ្រាកំណត់ (Deferred Net Settlement - DNS) និងអាចឱ្យអតិថិជនបានទទួលមូលនិធិកាន់តែរហ័ស (Near Real-Time Transfer - NRT) តាមរយៈការប្រើប្រាស់ស្តង់ដារ Message ISO 20022 និងដំណើរការប្រព័ន្ធជាលក្ខណៈ Straight Through Processing (STP)។ ស្តង់ដារ Message ISO 20022 ជាសារស្តង់ដារដែលប្រទេសក្នុងតំបន់អាស៊ានជ្រើសយកមកប្រើប្រាស់ សម្រាប់ការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់។ ចំណែកឯដំណើរការ STP ជាដំណើរការដែលសម្រួលដល់ការបញ្ជូនទិន្នន័យរវាងធនាគារជាសមាជិកទៅកាន់សភាផាត់ទាត់ជាតិកាន់តែរហ័ស សុវត្ថិភាព និងងាយស្រួល ជាពិសេសស្របតាមទិសដៅជំរុញការទូទាត់ជាអេឡិចត្រូនិក និងកាត់បន្ថយហានិភ័យប្រតិបត្តិការបង្កដោយកំហុសរបស់សមាជិក ក្នុងការវាយបញ្ចូលទៅក្នុងប្រព័ន្ធដោយដៃ (Human error) ដែលបច្ចុប្បន្នកំពុងមាននិន្នាការកើនឡើងជាលំដាប់។

### ក)- មូលប្បទានបត្រ (Checks)

បច្ចុប្បន្ននេះ មូលប្បទានបត្រនៅតែជាឧបករណ៍ទូទាត់សងប្រាក់មួយដែលពេញនិយម បើទោះបីជាការប្រើប្រាស់សាច់ប្រាក់ក្នុងសេដ្ឋកិច្ចនៅមានកម្រិតខ្ពស់។ ជាក់ស្តែង បើទោះបីជាចំនួនមូលប្បទានបត្រជាប្រាក់រៀលមានការថយចុះ ៩,៣៨% ក្តី (ពី ១៩.៨២៦ សន្លឹក ទៅ ១៧.៩៦៦ សន្លឹក)ក៏ចំនួនប្រាក់នៅតែមានការកើនឡើងប្រមាណ ១១៥% ពី ៦.៥១៥,៧១ ប៊ីលានរៀល ទៅ ១៤.០២៧,៧៥ ប៊ីលានរៀល។ ទន្ទឹមគ្នានោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់រៀលក៏មានការថយចុះ ៣៦,៥៥% (ពី ៩៣ សន្លឹក មកត្រឹម ៥៩ សន្លឹក) រីឯចំនួនប្រាក់របស់មូលប្បទានបត្របង្វិលវិញមានការកើនឡើងប្រមាណ ១៥៦% ពី ២៨,៩៦ ទៅ ៤.៥៥៣,២៩ ប៊ីលានរៀល។

យ៉ាងណាមិញ ចំពោះចំនួនមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានការថយចុះ ៥,៨១% ពី ៦៤៥.០១៥ សន្លឹក មកត្រឹម ៦០៧.៥១០ សន្លឹក ប៉ុន្តែចំនួនប្រាក់មានការកើនឡើងប្រមាណ ២៧,៥៨% ពី ២២.៨៤១,១១ លានដុល្លារអាមេរិក ទៅ ២៩.១៤១,៤៥ លានដុល្លារអាមេរិក។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់ដុល្លារអាមេរិក បានថយចុះ ១១,៣៥% ពី ៥.១៦០ សន្លឹក មកត្រឹម ៤.៥៧៤ សន្លឹក និងចំនួនប្រាក់កើនឡើង ២១,៥៤% ពី ៣៧០,០១ លានដុល្លារអាមេរិក ទៅ ៨.៣៤០,៤២ លានដុល្លារអាមេរិក។ មូលហេតុចម្បងដែលបណ្តាលឱ្យចំនួនមូលប្បទានបត្របង្វិលវិញកើនឡើង ដោយសារទិន្នន័យមូលប្បទានបត្រនិងអេឡិចត្រូនិកមានភាពមិនស៊ីគ្នា។

**តារាង ១ ៖ ការជាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់រៀល**

| ឆ្នាំ | មូលប្បទានបត្រជាប្រាក់រៀល | | មូលប្បទានបត្របង្វិលវិញ ជាប្រាក់រៀល | |
|---|---|---|---|---|
| | ចំនួន | ចំនួនប្រាក់ (គិតជាប៊ីលានរៀល) | ចំនួន | ចំនួនប្រាក់ (គិតជាប៊ីលានរៀល) |
| ឆ១-២០១៨ | ១៨.៧២២ | ៤.៦១១,៧០ | ៨៧ | ៤៦,៧៧ |
| ឆ២-២០១៨ | ១៩.៥២៧ | ៤.៨១២,៣៩ | ១១០ | ៩៩,៧៩ |
| ឆ១-២០១៩ | ១៩.៨២៦ | ៦.៥១៥,៧១ | ៩៣ | ២៨,៩៦ |
| ឆ២-២០១៩ | ២១.៨៧០ | ៧.០៨៧,០២ | ១១៣ | ១២៤,៦៧ |
| ឆ១-២០២០ | ១៧.៩៦៦ | ១៤.០២៧,៧៥ | ៥៩ | ៤.៥៥៣,២៩ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១ ៖ ចំនួនមូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញ ជាប្រាក់រៀល**







ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**តារាង ២ ៖ ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក**

| ឆ្នាំ | មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក | | មូលប្បទានបត្របង្វិលវិញ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ចំនួនប្រាក់ (គិតជាលានដុល្លារអាមេរិក) | ចំនួន | ចំនួនប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ១-២០១៨ | ៦០១.១៧០ | ១៧.៩៨៧,៩៧ | ៤.៨៨៣ | ៣១០,៧៧ |
| ឆ២-២០១៨ | ៦៣៧.០៦២ | ២៣.៤៧៤,៧៤ | ៥.៥៩១ | ២.៣៧៥,២៧ |
| ឆ១-២០១៩ | ៦៤៥.០១៥ | ២២.៨៤១,១១ | ៥.១៦០ | ៣៧០,០១ |
| ឆ២-២០១៩ | ៦៩២.៧៨៥ | ២៦,៧៦៧.៩៥ | ៥.៤៩៤ | ៣.៤០៩,៨៥ |
| ឆ១-២០២០ | ៦០៧.៥១០ | ២៩.១៤១,៤៥ | ៤.៥៧៤ | ៨.៣៤០,៤២ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២ ៖ ចំនួនមូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញ ជាប្រាក់ដុល្លារអាមេរិក**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

យោងតាមក្រាហ្វខាងលើ យើងសង្កេតឃើញថា ចំពោះឧបករណ៍មូលប្បទានបត្រ ដែលធ្វើប្រតិបត្តិការផាត់ទាត់ និងទូទាត់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិទាំងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកមានការថយចុះ ដែលឆ្លុះបញ្ចាំងអំពីនិន្នាការនៃការប្រើប្រាស់ឧបករណ៍បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិកកើនឡើង។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញបានថយចុះ ប៉ុន្តែចំនួនប្រាក់បានកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសដោយមូលហេតុ "ទិន្នន័យមូលប្បទានបត្រ និងអេឡិចត្រូនិកមិនស៊ីគ្នា"។ ការណ៍នេះ ទាមទារឱ្យសមាជិកត្រូវបង្កើនការប្រុងប្រយ័ត្នក្នុងការបញ្ចូលទិន្នន័យ ពិនិត្យឱ្យបានច្បាស់មុនបញ្ជូនមកសភាផាត់-ទាត់ជាតិ និងត្រូវមានវិធានការបន្ថែមទៀត ដើម្បីទប់ស្កាត់និងកាត់បន្ថយឱ្យបានជាអតិបរមានូវចំនួនមូលប្បទានបត្របង្វិលវិញ។

ដោយសារមូលប្បទានបត្រជាឧបករណ៍ទូទាត់សងប្រាក់ ដែលមានហានិភ័យខ្ពស់ ដូច្នេះហើយ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់បាន និងកំពុងអនុវត្តវិធានការមួយចំនួន ដើម្បីបន្តកាត់បន្ថយការប្រើប្រាស់មូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញ ដូចជា៖

- បង្កើនថ្លៃ ពិន័យ សម្រាប់មូលប្បទានបត្រគ្មានសំវិធានធន
- បង្កើនតម្លៃក្នុងការប្រើប្រាស់មូលប្បទានបត្រ
- លើកទឹកចិត្តឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក ដោយបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ដោយភាពងាយស្រួល តម្លៃសេវាថោក លឿន និងសុវត្ថិភាព
- បន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកពិនិត្យ និងកែសម្រួល ព្រមទាំងពង្រឹងការអនុវត្តលក្ខខណ្ឌទាក់ទងនឹងការប្រើប្រាស់មូលប្បទានបត្រ ដើម្បីបង្កើនការយកចិត្តទុកដាក់ និងការប្រុងប្រយ័ត្នរបស់អតិថិជនក្នុងការប្រើប្រាស់មូលប្បទានបត្រ។

### ខ)- បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក (Electronic Payment Orders)

ក្នុងរយៈពេលដូចគ្នានេះ ចំនួនប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលបានកើនឡើង ៧០,៨៧% (ពី ២.៥៤១ ទៅ ៤.៣៤២ បញ្ជាផ្ទេរ) ដែលមានចំនួនប្រាក់កើនឡើង ១៧,៣៥% (ពី ១.៩៩៤,៦១ ប៊ីលានរៀល ទៅ ២.៣៤០,៨៥ ប៊ីលានរៀល)។ ដោយឡែកចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក ក៏មានការកើនឡើង ២៤,៩៥% (ពី ១១២.៥៩១ ទៅ ១៤០.១២២ បញ្ជាផ្ទេរ) ស្របគ្នានឹងការកើនឡើងនូវចំនួនប្រាក់ប្រមាណ ១០% (ពី ៣.៦៨១,៤៨ លានដុល្លារអាមេរិក ទៅ ៤.០៤៩,៥៨ លានដុល្លារអាមេរិក)។

**តារាង ៣ ៖ បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធ NCS**

| ឆ្នាំ | បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិកជាប្រាក់រៀល | | បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិកជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ចំនួនប្រាក់ (គិតជាប៊ីលានរៀល) | ចំនួន | ចំនួនប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ១-២០១៨ | ២.៣៤៩ | ១.២១២,៧៨ | ៨០.៨៤០ | ៣.០១៤,៣៦ |
| ឆ២-២០១៨ | ២.៤៨៣ | ១.៦៩៣,៥៨ | ៩៨.២០២ | ៣.០១៣,៧៣ |
| ឆ១-២០១៩ | ២.៥៤១ | ១.៩៩៤,៦១ | ១១២.៥៩១ | ៣.៦៨១,៤៨ |
| ឆ២-២០១៩ | ៣.៧២៩ | ២.៣៣២,៣២ | ១២៣.០៤៥ | ៤.០៣០,០៩ |
| ឆ១-២០២០ | ៤.៣៤២ | ២.៣៤០,៨៥ | ១៤០.១២២ | ៤.០៤៩,៥៨ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣ ៖ បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ដោយសារការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិកនៅមានចំនួនតិច បើធៀបជាមួយមូលប្បទានបត្រ ដូច្នេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងដាក់ចេញគោលការណ៍មួយចំនួន ដើម្បីជំរុញការប្រើប្រាស់បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក ដូចខាងក្រោម៖

- ពង្រីកបណ្តាញផ្តល់សេវាបញ្ជាផ្ទេរប្រាក់តាមរយៈ Internet Banking ឬ Mobile Banking របស់ខ្លួនដើម្បីបង្កើនភាពងាយស្រួលសម្រាប់អតិថិជនប្រើប្រាស់
- លើកទឹកចិត្តក្នុងការប្រើប្រាស់បញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក តាមរយៈការយកកម្រៃប្រតិបត្តិការតិចជាងប្រតិបត្តិការមូលប្បទានបត្រ
- បន្តធ្វើទំនើបកម្ម និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់រាយថ្មីៗដែលងាយស្រួល និងមានសុវត្ថិភាពក្នុងការផ្ទេរប្រាក់ជាអេឡិចត្រូនិក។

## ៣.២. ប្រព័ន្ធទូទាត់សងប្រាក់ផ្សេងៗទៀត

ប្រព័ន្ធទូទាត់សងប្រាក់ផ្សេងៗទៀតដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារ-ជាតិនៃកម្ពុជារួមមាន៖

### ៣.២.១. ប្រព័ន្ធទូទាត់រហ័ស (Fast Payment System)

ប្រព័ន្ធទូទាត់រហ័ស បានដាក់ឱ្យដំណើរការដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ បំពេញតម្រូវការសាច់ប្រាក់របស់អតិថិជនបានទាន់ពេលវេលា និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ក្នុងឆមាសទី១ ឆ្នាំ២០២០ បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធទូទាត់រហ័សកើនឡើងពី ៤.៥១០ ទៅ ២១.៣៦៣ បញ្ជាផ្ទេរ និងចំនួនប្រាក់កើនឡើងប្រមាណ ៦% ពី ៩០,០១ ប៊ីលានរៀល ទៅ ៩៥,២៥ ប៊ីលានរៀល។

**តារាង ៤ ៖ បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ FAST**

| ឆ្នាំ | បញ្ជាផ្ទេរឥណទានជាប្រាក់រៀល | |
|---|---|---|
| | ចំនួន | ចំនួនប្រាក់ (គិតជាប៊ីលានរៀល) |
| ឆ១-២០១៨ | ២.៣៩២ | ៤០,៣៤ |
| ឆ២-២០១៨ | ៣.៦៦៣ | ៧៧,៣០ |
| ឆ១-២០១៩ | ៤.៥១០ | ៩០,០១ |
| ឆ២-២០១៩ | ១១.៥៤៨ | ១០០,២ |
| ឆ១-២០២០ | ២១.៣៦៣ | ៩៥,២៥ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤ ៖ បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ FAST**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ផ្អែកតាមទិន្នន័យខាងលើបង្ហាញថា ចំនួនប្រតិបត្តិការ និងទំហំប្រាក់ដែលធ្វើឡើងតាមរយៈប្រព័ន្ធ FAST មានការកើនឡើងជាង ៨ដង និង ៥,៨២% រៀងគ្នា ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។ ការណ៍នេះបង្ហាញថា អតិថិជនចាប់ផ្តើមស្គាល់ប្រព័ន្ធ និងយល់ពីអត្ថប្រយោជន៍នៃការប្រើប្រាស់បញ្ជាផ្ទេរឥណទាន ដែលជាឧបករណ៍ទូទាត់សងប្រាក់មានហានិភ័យទាប។

ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធនេះឱ្យបានកាន់តែមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបាននិងកំពុងជំរុញគ្រឹះស្ថានជាសមាជិកឱ្យពង្រីកបណ្តាញផ្តល់ “សេវាទូទាត់រហ័ស” របស់ខ្លួនតាមរយៈសេវាធនាគារអ៊ីនធើណេត និងសេវាធនាគារចល័ត (Internet/ Mobile Banking) និងតាមរយៈបណ្តាញ (Channel) ផ្សេងៗ និងបង្កើនការផ្សព្វផ្សាយ និងណែនាំអតិថិជនឱ្យបានជ្រួតជ្រាបកាន់តែច្បាស់ពីសេវាទូទាត់រហ័សនេះ ដើម្បីផ្តល់ភាពងាយស្រួលជាងមុនសម្រាប់អតិថិជនក្នុងការប្រើប្រាស់ប្រព័ន្ធនេះ។

### ៣.២.២. ប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch - CSS)

ប្រព័ន្ធ CSS ត្រូវបានអភិវឌ្ឍដើម្បីជាច្រកសម្រាប់សម្រួលប្រតិបត្តិការបណ្ណទូទាត់អន្តរធនាគារ និងសម្រាប់តភ្ជាប់ជាមួយប្រព័ន្ធ Switch របស់ប្រទេសដទៃទៀតក្នុងតំបន់។ ធនាគារជាតិនៃកម្ពុជាកំពុងពិចារណាអំពីលទ្ធភាពក្នុងការតភ្ជាប់ប្រព័ន្ធនេះទៅកាន់ប្រទេសក្នុងតំបន់ នៅពេលដែលប្រព័ន្ធ CSS មានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

សម្រាប់ឆមាសទី១ ឆ្នាំ២០២០ នេះ ប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់រៀលដែលបានចូលទូទាត់តាមប្រព័ន្ធ CSS បានកើនឡើងពី ២១.៦៩៩ ទៅ ៦៦.៥៩៥ ប្រតិបត្តិការ រីឯចំនួនប្រាក់ក៏មានការកើនឡើងពី ៣.៨៨២,៥២ លានរៀល ទៅ ១២.៨៦៨,៩៩ លានរៀល។ ជាមួយគ្នានេះ ចំនួនប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់ដុល្លារអាមេរិក ក៏មានការកើនឡើងពី ១៣.១៧៣ ទៅ ១៧.៤៧៣ ប្រតិបត្តិការ និងចំនួនប្រាក់កើនឡើងពី១.៤៦២.១៨៣,១២ ដុល្លារអាមេរិក ទៅ ១.៦៣៦.៨១០,៥៣ ដុល្លារអាមេរិក។

**តារាង ៥ ៖ ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS**

| ឆ្នាំ | ប្រតិបត្តិការប័ណ្ណឥណពន្ធ ជាប្រាក់រៀល | | ប្រតិបត្តិការប័ណ្ណឥណពន្ធ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការ | ចំនួនប្រាក់ (គិតជាលានរៀល) | ចំនួនប្រតិបត្តិការ | ចំនួនប្រាក់ |
| ឆ១-២០១៨ | 0 | 0 | 0 | 0 |
| ឆ២-២០១៨ | ២០.០២១ | ២៥៦,៨៣ | ៩.១៣៣ | ១.៤៨២.៩៩៦,០១ |
| ឆ១-២០១៩ | ២១.៦៩៩ | ៣.៨៨២,៤២ | ១៣.១៧៣ | ១.៤៦២.១៨៣,១២ |
| ឆ២-២០១៩ | ២៨.៣៥៩ | ៤.៩០២,០៦ | ១៤.៦៤៦ | ១.៥៣៨.១០១,៥៤ |
| ឆ១-២០២០ | ៦៦.៥៩៥ | ១២.៨៦៨,៤៩ | ១៧.៤៧៣ | ១.៦៣៦.៨១០,៥៣ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥ ៖ ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ៣.២.៣. ប្រព័ន្ធ Online Banking System (OBS)

ក្នុងឆមាសទី១ ឆ្នាំ២០២០ ប្រតិបត្តិការផ្ទេរប្រាក់តាមរយៈប្រព័ន្ធ OBS ជាប្រាក់រៀល រវាងគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាមានចំនួន ១១.៤៣៨ ប្រតិបត្តិការ ស្មើនឹងចំនួនប្រាក់ ៤៣ ទ្រីលានរៀល (កើនឡើង ៥៦,៧%) ហើយប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥.៣៣៨ ប្រតិបត្តិការ ដែលមានចំនួនប្រាក់ ១៥.៩៦១,៩០ លានដុល្លារអាមេរិក (កើនឡើង៣៩,៩%) បើធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។ ក្នុងរយៈពេលដូចគ្នា ប្រតិបត្តិការផ្ទេរប្រាក់តាមរយៈប្រព័ន្ធ OBS ជាប្រាក់រៀល ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តមានចំនួន ៣៦៥ ប្រតិបត្តិការ ដែលមានចំនួនប្រាក់ ១ ទ្រីលានរៀល និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៣៨១ ប្រតិបត្តិការ ស្មើនឹងចំនួនប្រាក់ ៣២៧,០២ លានដុល្លារអាមេរិក (កើនឡើង ៦២,៧%) បើធៀបទៅនឹងឆមាសទី១ ឆ្នាំ២០១៩។

**តារាង ៦ ៖ ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល តាមប្រព័ន្ធ OBS**

| ឆ្នាំ | ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល | | | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការប្រាក់រៀល | ចំនួនប្រាក់ (គិតជាប៊ីលានរៀល) | ចំនួនប្រតិបត្តិការប្រាក់ដុល្លារអាមេរិក | ចំនួនប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ១-២០១៨ | ៣.៥៧៨ | ៣ | ១.៨១៩ | ៥.៦២៩,០៦ |
| ឆ២-២០១៨ | ៤.៧២៩ | ១០,៨ | ២.៦៧៧ | ៩.០៩៥,៨៧ |
| ឆ១-២០១៩ | ៦.៨០៧ | ២៤,៤៥ | ៣.៣៨០ | ១១.៤០៨,៧១ |
| ឆ២-២០១៩ | ៧.៥៤៤ | ២៥,៧៩ | ៤.៥៤៣ | ១៤.៣៩៥,៥៥ |
| ឆ១-២០២០ | ១១.៤៣៨ | ៤៣ | ៥.៣៣៨ | ១៥.៩៦១,៩០ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**តារាង ៧ ៖ ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត តាមប្រព័ន្ធ OBS**

| ឆ្នាំ | ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត | | | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការប្រាក់រៀល | ចំនួនប្រាក់ (គិតជាប៊ីលានរៀល) | ចំនួនប្រតិបត្តិការប្រាក់ដុល្លារអាមេរិក | ចំនួនប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ១-១៨ | ២៨៦ | ០,៨ | ៩៩ | ១១៦,២០ |
| ឆ២-១៨ | ២៦៣ | ០,៩ | ១២២ | ១៦៥,៧២ |
| ឆ១-១៩ | ២៧៨ | ១ | ១១៤ | ២០១,០៦ |
| ឆ២-១៩ | ៣៨០ | ១,៤ | ២១៦ | ២៩០,២១ |
| ឆ១-២០ | ៣៦៥ | ១ | ៣៨១ | ៣២៧,០២ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦ ៖ ការផ្ទេរប្រាក់ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក តាមប្រព័ន្ធ OBS**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

បើទោះបីជាប្រព័ន្ធ Online Banking នេះបានដាក់ឱ្យដំណើរការរយៈពេលប្រមាណ ៤ ឆ្នាំ ហើយយ៉ាងណាក្តី ក៏យើងសង្កេតឃើញថា ប្រព័ន្ធនេះនៅពុំទាន់បានប្រើប្រាស់ទូលំទូលាយ

នៅឡើយទេ ដោយសារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅតែជ្រើសរើសប្រើប្រាស់ប្រតិបត្តិការផ្ទេរប្រាក់ធ្វើដោយដៃ (Manual) និងភាគីពាក់ព័ន្ធមានតម្រូវការក្នុងការរក្សាឯកសារជាលាយលក្ខណ៍អក្សរទុកជាឯកសារយោងសម្រាប់ប្រើប្រាស់។ ក្នុងគោលបំណងជំរុញឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់ប្រព័ន្ធនេះ អោយបានកាន់តែមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាកំពុងពិចារណាលើគោលការណ៍បង្កើនកម្រៃការបង់ប្រាក់តាមបញ្ជរ និងការប្រើប្រាស់មូលប្បទានបត្រ ព្រមទាំងកំណត់ទំហំប្រាក់អតិបរមាលើមូលប្បទានបត្រ ដោយផ្តល់អាទិភាព និងជម្រើសឱ្យគ្រឹះស្ថានជាសមាជិក ផ្ទេរប្រាក់តាមរយៈប្រព័ន្ធ Online Banking វិញ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជានឹងសិក្សាពីលទ្ធភាពដាក់ឱ្យគ្រឹះស្ថានសាធារណៈប្រើប្រាស់ប្រព័ន្ធនេះផងដែរ ដើម្បីសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ឱ្យកាន់តែងាយស្រួល។

### ៣.២.៤. ប្រព័ន្ធរីថែលផេ (Retail Pay)

ដោយសារតែប្រព័ន្ធ Retail Pay ទើបតែបានដាក់ឱ្យដំណើរការបឋមក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ កន្លងទៅនេះ ដូច្នេះប្រតិបត្តិការរបស់ប្រព័ន្ធនេះនៅមានកម្រិតនៅឡើយ។ បច្ចុប្បន្ន ក្នុងចំណោមប្រព័ន្ធទាំង៤ (១-ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ-RFT ២-ប្រព័ន្ធទូទាត់ចល័ត-MPS ៣-ប្រព័ន្ធទូទាត់តាមQR-QPS និង ៤-ប្រព័ន្ធជាត់ទាត់អេឡិចត្រូនិក-ECS) ក្នុងកំឡុងពេលដំណើរការបឋមនេះ មានតែប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (RFT) ប៉ុណ្ណោះ ដែលដាក់ឱ្យប្រើប្រាស់ ចំណែកប្រព័ន្ធផ្សេងទៀតកំពុងធ្វើសន្ទានកម្មនៅឡើយ។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ នេះ ប្រព័ន្ធ RFT បានដំណើរការទូទាត់លើប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកចំនួន ១០៣ថ្ងៃ ដែលចំនួនប្រតិបត្តិការជាប្រាក់រៀលមានសរុបចំនួន ១.៧២០ ប្រតិបត្តិការ គិតជាប្រាក់ស្មើនឹង ១០.៧០៣,២៣ លានរៀល និងចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ២.៧៩៧ ប្រតិបត្តិការ ស្មើនឹង ១៦,០៧ លានដុល្លារអាមេរិក។

**តារាង ៨ ៖ ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT**

| ឆ្នាំ | បញ្ជាផ្ទេរ ជាប្រាក់រៀល | | បញ្ជាផ្ទេរ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ចំនួនប្រាក់ (គិតជាលានរៀល) | ចំនួន | ចំនួនប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| មករា - ២០២០ | 0 | 0 | 0 | 0 |
| កុម្ភៈ - ២០២០ | ៦៧ | ១.១០៥,៥៧ | ២១៥ | ២,០៦ |
| មីនា - ២០២០ | ១១៧ | ៤.០៥០,៦៨ | ៣៤៥ | ២,៥៧ |
| មេសា - ២០២០ | ១២៦ | ៣៨៤,៤០ | ៤៧៤ | ៣,៣៥ |
| ឧសភា - ២០២០ | ៧២០ | ២.៤២៨,៧១ | ៧៤២ | ៤,៣៧ |
| មិថុនា - ២០២០ | ៦៩០ | ២.៧៣៣,៨៧ | ១.០២១ | ៣,៧៣ |

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧ ៖ ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក តាមប្រព័ន្ធ RFT**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៣.៣. ការវាយតម្លៃប្រព័ន្ធទូទាត់សងប្រាក់

ធនាគារកណ្តាលមានតួនាទីក្នុងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីធានាបាននូវសុវត្ថិភាព និងប្រសិទ្ធភាពរបស់ប្រព័ន្ធ ក៏ដូចជាការការពារពីហានិភ័យនានាដែលអាចនឹងកើតមានឡើង។ ប្រព័ន្ធទូទាត់សងប្រាក់អនុញ្ញាតឱ្យមានប្រតិបត្តិការផ្ទេរប្រាក់រវាងបុគ្គលអាជីវកម្ម និងទីផ្សារហិរញ្ញវត្ថុបានយ៉ាងឆាប់រហ័ស និងមានសុវត្ថិភាព។

ការវាយតម្លៃប្រព័ន្ធទូទាត់សងប្រាក់ មានគោលបំណងកាត់បន្ថយហានិភ័យចម្បងៗក្នុងប្រព័ន្ធទូទាត់សងប្រាក់ដូចជា ហានិភ័យប្រតិបត្តិការ ហានិភ័យទូទាត់ ហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន ហានិភ័យជាប្រព័ន្ធ និងហានិភ័យទីផ្សារប្តូរប្រាក់។ ទន្ទឹមនឹងនោះ ការវាយតម្លៃនេះធ្វើឡើងដើម្បីកែលម្អប្រព័ន្ធផាត់ទាត់ឱ្យកាន់តែមានសុវត្ថិភាព និងប្រសិទ្ធភាពថែមទៀត ស្របតាមនិន្នាការវិវត្តន៍ថ្មីៗនៃប្រព័ន្ធទូទាត់ក្នុងសកលលោក។ ប្រព័ន្ធទូទាត់សងប្រាក់សំខាន់ៗ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងវាយតម្លៃមានដូចជាប្រព័ន្ធ NCS ប្រព័ន្ធ FAST ប្រព័ន្ធ NBCP និងប្រព័ន្ធ CSS។

ស្ថិតក្នុងដំណាក់កាលដំបូង ធនាគារជាតិនៃកម្ពុជា បានធ្វើការវាយតម្លៃលើប្រព័ន្ធផាត់ទាត់ជាតិ ដែលជាប្រព័ន្ធទូទាត់សំខាន់ (SIPS)។ ប្រព័ន្ធផាត់ទាត់ជាតិ គឺជាប្រព័ន្ធទូទាត់ចម្បងនៅក្នុងប្រទេសកម្ពុជាដែលធ្វើការទូទាត់ប្រមូលផ្តុំ មានឧបករណ៍ទូទាត់ច្រើន មានទំហំប្រាក់ធំ និងចំនួនប្រតិបត្តិការច្រើន។ ដូច្នេះ ប្រសិនបើប្រព័ន្ធទូទាត់ចម្បងនេះជួបបញ្ហារាំងស្ទះ ជាប់គាំង ឬមិនដំណើរការនៅពេលណាមួយ នោះនឹងបណ្តាលឱ្យប៉ះពាល់ដល់ប្រព័ន្ធផ្សេងៗទៀត ទីបំផុតនឹងបណ្តាលឱ្យមានហានិភ័យដួលរលំជាប្រព័ន្ធ ដែលជាហេតុនាំឱ្យរាំងស្ទះដល់ដំណើរការទូទាត់នៅក្នុងប្រទេស។ ដោយពិនិត្យឃើញចំណុចសំខាន់ខាងលើនេះ ធនាគារជាតិនៃកម្ពុជាបានជ្រើសរើសយកប្រព័ន្ធទូទាត់នេះមកវាយតម្លៃ។

# ៤. ប្រតិបត្តិការសេវាទូទាត់សងប្រាក់

នៅប្រទេសកម្ពុជា សេវាទូទាត់សងប្រាក់មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ យើងអាចសង្កេតឃើញ តាមរយៈការកើនឡើងចំនួនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់នៅក្នុងបរិស្ថានទីផ្សារទូទាត់។ ការរីកចម្រើននៃសេវា និងឧបករណ៍ទូទាត់ថ្មីៗទាំងនេះ បានជួយលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ជំរុញការប្រកួតប្រជែង លើក-កម្ពស់ភាពច្នៃប្រឌិត និងផ្តល់នូវជំនឿទុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់សេវាទូទាត់សងប្រាក់។

ធនាគារជាតិនៃកម្ពុជាបានរៀបចំនីតិវិធីក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ឱ្យស្របទៅតាមស្តង់ដារអន្តរជាតិ និងការអនុវត្តឱ្យមានប្រសិទ្ធភាពទៅតាមគោលការណ៍របស់ធនាគារកណ្តាល។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលមិនមែនជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ៤.១. គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់

ក្នុងឆ្នាំ២០២០ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតក្នុងការផ្តល់សេវាទូទាត់មានចំនួន ៣ គ្រឹះស្ថាន ដោយគ្រឹះស្ថាននីមួយៗបានអនុវត្តយកគំរូអាជីវកម្មដូចៗគ្នាក្នុងការផ្តល់សេវាទូទាត់ដល់សាធារណជន រួមមាន ការផ្ទេរប្រាក់ ដក/ដាក់ប្រាក់ក្នុងគណនីកាបូបអេឡិចត្រូនិក ទូទាត់តម្លៃវាយ ទូទាត់វិក្កយបត្រ ទូទាត់សងកម្ចី និងទូទាត់អនឡាញ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ ចំនួនប្រតិបត្តិការសរុបមាន ៩០,៩ លានប្រតិបត្តិការ និងមានទំហំប្រាក់ ១៧,២ ប៊ីលានដុល្លារអាមេរិក។ ចំពោះភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ១២,៩ ពាន់ភ្នាក់ងារ និងចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់គណនីកាបូបអេឡិច-ត្រូនិកជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមាន ៤,៨ លានគណនី។

**ក្រាហ្វ ៨ ៖ ចំនួនប្រតិបត្តិការ និង ទំហំប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៩ ៖ ចំនួនប្រកទូទាត់ និងអតិថិជនចុះឈ្មោះគណនីកាបូបអេឡិចត្រូនិករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៤.២. គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

បច្ចុប្បន្ន គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ ដោយគិតត្រឹមឆមាសទី១ ឆ្នាំ២០២០ មានចំនួន ២៣ គ្រឹះស្ថាន។ ក្នុងនោះ ចំនួនប្រតិបត្តិការរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់សរុបមាន ២៨,៩ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ២,៨ ប៊ីលានដុល្លារអាមេរិក។ រីឯចំនួនភ្នាក់ងាររបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានការកើនឡើងពី ២៥,៤ ពាន់ មក ២៨,៧ ពាន់ភ្នាក់ងារ និងចំនួនអតិថិជនចុះឈ្មោះគណនីកាបូបអេឡិចត្រូនិកកើនពី ១,៣ ដល់ ២,១១ លានគណនី បើធៀបទៅនឹងឆមាសទី១ ឆ្នាំ២០១៩។

**ក្រាហ្វ ១០ ៖ ចំនួនប្រតិបត្តិការ និង ទំហំប្រាក់របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១១ ៖ ចំនួនច្រកទូទាត់ និងអតិថិជនចុះឈ្មោះគណនីកាបូបអេឡិចត្រូនិករបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៤.៣. ឧបករណ៍ទូទាត់

### ៤.៣.១. សេវាធនាគារអេឡិចត្រូនិក (Electronic Banking)

បច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាបានដាក់ឱ្យអតិថិជនប្រើប្រាស់យ៉ាងទូលំទូលាយនូវសេវាធនាគារអ៊ីនធើណេត (Internet Banking) និងសេវាធនាគារចល័ត (Mobile Banking) ដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការជាច្រើនរួមមាន ការទូទាត់ឥណទាន ការទូទាត់វិក្កយបត្រ (ថ្លៃទឹក អគ្គិសនី អ៊ីនធើណេត ទូរទស្សន៍ខ្សែកាប) សេវាបញ្ចូលប្រាក់ទូរស័ព្ទ សេវាបើកប្រាក់បៀវត្សរ៍ និងសេវាទូទាត់ផ្សេងៗទៀតដូចជាការផ្ទេរមូលនិធិ និងការពិនិត្យមើលសមតុល្យនៅក្នុងគណនីជាដើម។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២៧ គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធើណេត និងគ្រឹះស្ថានចំនួន ២៣ ផ្តល់សេវាធនាគារចល័ត។ ក្នុងនោះ ចំនួនប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធើណេតមានចំនួន ១,១ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ៥,១ ប៊ីលានដុល្លារអាមេរិក។ រីឯ ចំនួនប្រតិបត្តិការរបស់សេវាធនាគារចល័តមានចំនួន ៥៥,២ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ២២,១ ប៊ីលានដុល្លារអាមេរិក។

**ក្រាហ្វ ១២ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់របស់សេវាធនាគារអេឡិចត្រូនិក**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ៤.៣.២. ប័ណ្ណទូទាត់ និងច្រកទូទាត់

ប័ណ្ណទូទាត់ ជាឧបករណ៍ទូទាត់អេឡិចត្រូនិកដែលកំពុងពេញនិយមសម្រាប់ការទូទាត់តម្លៃរាយ និងអនឡាញ។ ប័ណ្ណទូទាត់មានចំនួន ៤ ប្រភេទរួមមាន ប័ណ្ណឥណពន្ធ (Debit Card) ប័ណ្ណឥណទាន (Credit Card) ប័ណ្ណដកនិងដាក់ប្រាក់តាមម៉ាស៊ីនស្វ័យប្រវត្តិ (ATM Card) និងប័ណ្ណបង់ប្រាក់ជាមុន (Prepaid Card)។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២០ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៨ គ្រឹះស្ថាន បានចេញផ្សាយប័ណ្ណទូទាត់អោយអតិថិជនប្រើប្រាស់ ដើម្បីផ្តល់នូវភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការទូទាត់។ ក្នុងនោះ ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយសរុបមាន ៦,៨ លានប័ណ្ណ និងប្រតិបត្តិការប័ណ្ណទូទាត់នៅក្នុងស្រុក (Domestic) មានចំនួន ៣៦,៣ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ៧,៨ ប៊ីលានដុល្លារអាមេរិក។ ចំពោះការធ្វើប្រតិបត្តិការប័ណ្ណទូទាត់នៅក្រៅស្រុក (Out Bounce) មានចំនួន ២,៨ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ០,២២ ប៊ីលានដុល្លារអាមេរិក។ រីឯ ប្រតិបត្តិការទូទាត់ទំនិញតាមអនឡាញ (Online) មានចំនួន ៣,៨ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ០,១៥ ប៊ីលានដុល្លារអាមេរិក។ ជាមួយគ្នានេះ ប្រទេសកម្ពុជាមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៩ បានតម្លើងម៉ាស៊ីនដក/ដាក់ប្រាក់ (ATM) មានចំនួន ២,៨ ពាន់គ្រឿង និងម៉ាស៊ីនឆូតកាត (POS) ចំនួន ២២,១ ពាន់គ្រឿង។

**ក្រាហ្វ ១៣ ៖ ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៤ ៖ ចំនួនម៉ាស៊ីន ATM និង ម៉ាស៊ីនឆូតកាត POS ដែលបានតម្លើង**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ៤.៣.៣. ការទូទាត់តាម ឃ្យូ អរ កូត (QR Code Payment)

បច្ចុប្បន្ននៅប្រទេសកម្ពុជា ការប្រើប្រាស់ QR កូត ដើម្បីទូទាត់ទំនិញ និងសេវានានាកាន់តែពេញនិយម ដោយសារភាពងាយស្រួល និងសុវត្ថិភាពរបស់សេវានេះ ធ្វើឱ្យអតិថិជនកាន់តែមានទំនុកចិត្តក្នុងការប្រើប្រាស់ការទូទាត់តាម QR កូត។ ក្នុងឆមាសទី១ ឆ្នាំ២០២០ នេះ ប្រតិបត្តិការទូទាត់តាម QR កូត មានចំនួន ២,៣ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ៣០,១ លានដុល្លារអាមេរិក។

ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេ អេច ឃ្យូ អរ កូត (KHQR Code) ដើម្បីសម្រួលដល់ការទូទាត់តាម QR កូត។

**ក្រាហ្វ ១៥ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR កូត**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៥. ការផ្ទេរប្រាក់ និងការទូទាត់ឆ្លងដែន

### ៥.១. ប្រតិបត្តិការតាមប្រព័ន្ធស្វីស (SWIFT)

ប្រតិបត្តិការផ្ទេរប្រាក់តាមរយៈប្រព័ន្ធស្វីស ធ្វើឡើងតាមបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ប្រតិបត្តិការតាមប្រព័ន្ធស្វីស ភាគច្រើនពាក់ព័ន្ធនឹងការទូទាត់ទំនិញក្នុងការធ្វើពាណិជ្ជកម្ម។ ក្នុងឆមាសទី១ ឆ្នាំ២០២០ ចំនួនប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធស្វីស សរុប ០,៣៩ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ២៤,៥ ប៊ីលានដុល្លារអាមេរិក។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្រុកចំនួន ៣៨ ដែលកំពុងផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធស្វីសនេះ។

**ក្រាហ្វ ១៦ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធស្វីស**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៥.២. ប្រតិបត្តិការតាមអ្នកដំណើរការតតិយភាគី (Third Party Processor)

បច្ចុប្បន្ន អ្នកដំណើរការតតិយភាគីចំនួន ០៤ បានផ្តល់នូវសេវាផ្ទេរប្រាក់ឆ្លងព្រំដែនរួមមាន Western Union, Money Gram, IREMIT និង Express Money។ ជាទូទៅ អ្នកដំណើរការ-តតិយភាគីទាំងនេះ បម្រើដល់ការផ្ទេរប្រាក់របស់ពលករកម្ពុជាពីប្រទេសថៃ ម៉ាឡេស៊ី កូរ៉េ និងប្រទេសជិតខាងផ្សេងទៀតមកកាន់ក្រុមគ្រួសារដែលស្នាក់នៅក្នុងប្រទេសកម្ពុជា។ ការប្រើប្រាស់បណ្តាញផ្ទេរប្រាក់ជាផ្លូវការនេះ ផ្តល់នូវភាពងាយស្រួលដល់ពលករចំណាកស្រុកក្នុងការផ្ទេរប្រាក់ ដើម្បីទ្រទ្រង់ជីវភាពរបស់ក្រុមគ្រួសារ។ ក្នុងឆមាសទី១ ឆ្នាំ២០២០ ប្រតិបត្តិការផ្ទេរប្រាក់របស់អ្នកដំណើរការតតិយមានចំនួនសរុប ០,៤៤ លានប្រតិបត្តិការ និងមានទំហំប្រាក់សរុបចំនួន ០,៣ ប៊ីលានដុល្លារអាមេរិក និងមានអតិថិជនធ្វើប្រតិបត្តិការផ្ទេរប្រាក់សរុបមានចំនួន ០,៤ លាននាក់។

**ក្រាហ្វ ១៧ ៖ ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ តាមរយៈអ្នកដំណើរការតតិយភាគី**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៥.៣. របាយការណ៍ការផ្ទេរប្រាក់ឯកជនឆ្លងដែនតាមប្រព័ន្ធ ITRS

ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធរបាយការណ៍ ITRS ក្នុងឆ្នាំ២០០៣ ក្នុងគោលបំណងផ្តល់មធ្យោបាយដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់រាយការណ៍អំពីការផ្ទេរប្រាក់ឯកជនឆ្លងដែន។ បច្ចុប្បន្នមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥១ បានធ្វើរបាយការណ៍តាមរយៈប្រព័ន្ធ ITRS។ ការផ្ទេរប្រាក់ឯកជនឆ្លងដែន ជាការផ្ទេរប្រាក់ផ្លូវការជាអេឡិចត្រូនិកចម្បងមួយ តាមរយៈប្រព័ន្ធគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ នៅប្រទេសកម្ពុជា ការផ្ទេរប្រាក់ឯកជនឆ្លងដែនភាគច្រើនធ្វើឡើងដោយពលករចំណាកស្រុកទៅក្រៅប្រទេស។ ក្នុងឆមាសទី១ ឆ្នាំ២០២០ ពលករចំណាកស្រុកបានផ្ទេរប្រាក់មកក្រុមគ្រួសារពីប្រទេសថៃប្រមាណ ៧៤,៤៤% នៃទំហំផ្ទេរប្រាក់ឯកជនឆ្លងដែនសរុប ហើយប្រទេសកូរ៉េខាងត្បូងចំនួន ១៥,៥៣% និងបន្តដោយប្រទេសជប៉ុន ៦,០៦% និងប្រទេសម៉ាឡេស៊ី ១,៣៤%។ ធនាគារជាតិនៃកម្ពុជាដែលជាបញ្ញត្តិករ និងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ឱ្យប្រើប្រាស់ផលិតផលថ្មីៗ ប្រកបដោយនវានុវត្តន៍ ដើម្បីលើកកម្ពស់ការប្រកួតប្រជែង និងរួមចំណែកធ្វើឱ្យការផ្តល់សេវាផ្ទេរប្រាក់កាន់តែមានកម្រៃទាប ងាយស្រួល ឆាប់រហ័ស និងមានតម្លាភាពសម្រាប់អតិថិជន ទាំងនេះជាកត្តាសំខាន់ ក្នុងការលើកទឹកចិត្តឱ្យសាធារណជនងាកមកប្រើប្រាស់សេវាផ្ទេរប្រាក់តាមបណ្តាញផ្លូវការវិញ។

**ក្រាហ្វ ១៨ ៖ ទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឯកជនឆ្លងដែន ចូល/ចេញ ប្រទេសកម្ពុជា (គិតជាភាគរយ %)**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ប្រអប់ ១៧ ៖ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ

ការរីកចម្រើននៃបច្ចេកវិទ្យាដែលរួមមាន ទូរស័ព្ទចល័ត ប្រព័ន្ធអ៊ីនធើណែត បច្ចេកវិទ្យាប្លុកឆែន (Blockchain) បញ្ញានិមិត្ត (Artificial Intelligence) ឃ្លាំងទិន្នន័យ (Data Storage) ការវិភាគទិន្នន័យ (Data Analytic) បច្ចេកវិទ្យាជីវមាត្រ (Biometric Technology) រួមទាំង បច្ចេកវិទ្យាសម្រួលដល់ការត្រួតពិនិត្យផ្សេងៗ បានជំរុញឱ្យមានការរីកចម្រើនក្នុងវិស័យហិរញ្ញវត្ថុ ដែលការណ៍នេះ ត្រូវបានទទួលស្គាល់ជាទូទៅថាជាបច្ចេកវិទ្យាហិរញ្ញវត្ថុ។ បច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនបង្គួរនៅក្នុងវិស័យមួយចំនួន ដូចជា ប្រព័ន្ធទូទាត់ ការផ្ទេរប្រាក់ឆ្លងព្រំដែន និងការផ្តល់ឥណទាន ប៉ុន្តែ វិស័យផ្សេងទៀតមានការលូតលាស់តិចតួចប៉ុណ្ណោះ។ ការដាក់ចេញនូវបច្ចេកវិទ្យាទាំងនេះ បានផ្តល់នូវកាលានុវត្តភាព ក្នុងការជំរុញឱ្យមានប្រសិទ្ធភាពថែមទៀតនៅក្នុងវិស័យហិរញ្ញវត្ថុ ពាក់ព័ន្ធការចំណាយថ្លៃដើម ល្បឿន សុវត្ថិភាព និងតម្លាភាព ការជំរុញលទ្ធភាពក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុ ក៏ដូចជាការជំរុញឱ្យមានបរិវត្តន៍នៃសេវាកម្មហិរញ្ញវត្ថុ។

ទោះជាយ៉ាងនេះក្តី បច្ចេកវិទ្យាហិរញ្ញវត្ថុក៏ជំរុញឱ្យមានបញ្ហាប្រឈមមួយចំនួនផងដែរ ពាក់ព័ន្ធបទល្មើសតាមប្រព័ន្ធអ៊ីនធើណែត កិច្ចការពារអតិថិជន និងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ម្យ៉ាងវិញទៀត បច្ច័យ និងឥទ្ធិពលនៃបច្ចេកវិទ្យាហិរញ្ញវត្ថុចំពោះការអនុវត្តគោលនយោបាយរូបិយវត្ថុ និងស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារកណ្តាលមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ។ ឥទ្ធិពលទាំងនេះមានភាពផ្សេងៗគ្នាទៅតាមស្ថានភាព និងបុរេលក្ខខណ្ឌនៃប្រទេសនីមួយៗ។ ដោយមើលឃើញពីកាលានុវត្តភាពនៅក្នុងស្ថានភាពកម្ពុជា ធនាគារជាតិនៃកម្ពុជាបានខិតខំដាក់ចេញនូវគោលនយោបាយសមស្រប ដើម្បីលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការដាក់ចេញបទប្បញ្ញត្តិសមស្របក្នុងការជំរុញការចូលរួម និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាបន្ធូរបន្ថយហានិភ័យនានាដែលអាចកើតមានឡើង។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយដៃគូអភិវឌ្ឍមួយចំនួន ក្នុងការកសាងបរិស្ថានសមស្របសម្រាប់អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ដូចជា ផែនទីមគ្គុទ្ទេសក៍ស្តីពី បច្ចេកវិទ្យាហិរញ្ញវត្ថុក៏កំពុងត្រូវបានរៀបចំ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

ធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍគម្រោងបាគងដែលជាផ្នែកមួយ ក្នុងការជំរុញបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងគោលដៅលើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពប្រព័ន្ធទូទាត់សងប្រាក់នៅប្រទេសកម្ពុជា។ គោលបំណងនៃការអភិវឌ្ឍប្រព័ន្ធនេះ គឺដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនសេដ្ឋកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន កាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ក្នុងទីផ្សារ និងចូលរួមលើកកម្ពស់ បរិយាប័ន្នហិរញ្ញវត្ថុ។ គម្រោង "បាគង" នេះ ពិនិត្យលទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា Blockchain សម្រាប់ប្រតិបត្តិការទូទាត់រវាងបុគ្គលនិងបុគ្គល ដោយមិនឆ្លងកាត់ប្រព័ន្ធស្នូលសម្រាប់ការផាត់ទាត់និងទូទាត់ចុងក្រោយឡើយ និងអនុញ្ញាតឱ្យមានប្រតិបត្តិការឆ្លង (Interoperability) ផងដែរ។

គិតត្រឹមខែមិថុនា ឆ្នាំ២០២០ មានគ្រឹះស្ថានចំនួន ១៤ បានដាក់ដំណើរការសាកល្បងប្រព័ន្ធបាគង និង ២៥ គ្រឹះស្ថានផ្សេងទៀតបានគោលការណ៍អនុញ្ញាតចូលជាសមាជិកក្នុងប្រព័ន្ធបាគង។

ក្នុងក្របខណ្ឌអភិវឌ្ឍប្រព័ន្ធទូទាត់និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយធនាគារកណ្តាលថៃ ពិនិត្យលើគម្រោងអភិវឌ្ឍការទូទាត់ឆ្លងព្រំដែនរវាងប្រទេសថៃ និងប្រទេសកម្ពុជា ដោយប្រើប្រាស់រូបិយវត្ថុក្នុងស្រុក ដើម្បីសម្រួលដល់សកម្មភាពសេដ្ឋកិច្ច និងការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។ គម្រោងនេះ នឹងសិក្សាអំពីការតភ្ជាប់ប្រព័ន្ធទូទាត់របស់ប្រទេសទាំងពីរ ប្រើប្រាស់ស្តង់ដាររួមដែលអាចធ្វើប្រតិបត្តិការឆ្លងគ្នាបាន ក៏ដូចជាការធ្វើសុខដុមភាវូបនីយកម្មលើក្របខណ្ឌបទប្បញ្ញត្តិ ដើម្បីជំរុញប្រសិទ្ធភាព និងសុវត្ថិភាពនៅក្នុងការទូទាត់ ផាត់ទាត់ និងផ្ទេរប្រាក់។ ដើម្បីឱ្យការទូទាត់ឆ្លងដែនអាចប្រព្រឹត្តិទៅបានតម្រូវឱ្យមានការប្រើប្រាស់ស្តង់ដាររួមមួយ ហេតុនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់។

# ៦. ការសន្និដ្ឋាន និងបញ្ហាប្រឈម

សរុបមក សមិទ្ធិផលដែលទទួលបានកន្លងមកនេះ អាស្រ័យជាចម្បងដោយធនាគារជាតិនៃកម្ពុជាបានអនុវត្តកម្មវិធីកំណែទម្រង់ជាបន្តបន្ទាប់លើវិស័យធនាគារ ដើម្បីជំរុញនិងបង្កើនជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធធនាគារ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានរៀបចំក្របខណ្ឌបទប្បញ្ញត្តិ ដែលផ្តល់លក្ខខណ្ឌល្អប្រសើរសម្រាប់សេវាទូទាត់ និងសេវាធនាគារតាមទូរស័ព្ទចល័តដែលជាកត្តាមួយជំរុញឱ្យមានកំណើននៃអ្នកផ្តល់សេវាទូទាត់តាមទូរស័ព្ទចល័តបន្ថែមលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ដោយយល់ឃើញពីសារៈសំខាន់របស់ប្រព័ន្ធទូទាត់ ក្នុងការជួយសម្រួលដល់កិច្ចដំណើរការរបស់ប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់ប្រទេសទាំងមូល ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំនិងដាក់ចេញឱ្យអនុវត្តនូវបទប្បញ្ញត្តិ និងបទដ្ឋានណែនាំបន្ថែមទៀតពាក់ព័ន្ធនឹងប្រតិបត្តិការប្រព័ន្ធទូទាត់។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងកសាងសមត្ថភាពមន្ត្រីបុគ្គលិក ដាក់ឱ្យអនុវត្តក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់ និងរៀបចំនីតិវិធី ត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់បន្ថែមទៀត ដើម្បីអនុវត្តមុខងារត្រួត-ពិនិត្យប្រព័ន្ធនិងសេវាទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងគោលដៅការពារផលប្រយោជន៍អតិថិជន និងបង្កើនជំនឿទុកចិត្តលើប្រព័ន្ធទូទាត់។ ក្នុងក្របខណ្ឌនៃការអភិវឌ្ឍ ធនាគារជាតិនៃកម្ពុជាក៏កំពុងយកចិត្តទុកដាក់ជាខ្លាំង ក្នុងការដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ (ប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស ប្រព័ន្ធខេមបូខានស្វ៊ិច ប្រព័ន្ធបាគង និងប្រព័ន្ធរីធែលផេ) និងជំរុញការប្រើប្រាស់ប្រព័ន្ធដែលបានអភិវឌ្ឍដើម្បីសម្រួលដល់ការទូទាត់អន្តរ-ធនាគារ និងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ាន។ ទន្ទឹមនោះដែរ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដុលភ្លាមៗ ដើម្បីសម្រួលដល់ការទូទាត់តម្លៃធំ និងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនាពេលអនាគត។

ស្របពេលដែលធនាគារជាតិនៃកម្ពុជាសម្រេចបានសមិទ្ធិផលចម្បងៗ ក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា បញ្ហាប្រឈមពាក់ព័ន្ធនឹងការអភិវឌ្ឍនេះក៏មិនអាចកាត់ផ្តាច់បានទេ។ ជាក់ស្តែង បញ្ហាជាសារវន្តពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ការរៀបចំក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ ការត្រួតពិនិត្យប្រព័ន្ធនិងសេវាទូទាត់សងប្រាក់ និងការដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រជំរុញការផ្ទេរប្រាក់ឆ្លងព្រំដែន និងបច្ចេកវិទ្យាហិរញ្ញវត្ថុចាំបាច់ត្រូវពង្រឹងបន្ថែមទៀត។ គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរួមមាន ប្រព័ន្ធរីធែលផេ ប្រព័ន្ធទូទាត់តម្លៃធំ ប្រព័ន្ធបាគងជាដើម ត្រូវបានអនុវត្តទន្ទឹមគ្នាដែលធ្វើឱ្យការបែងចែកធនធានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានជាសមាជិកមិនមានភាពរលូន ព្រមទាំងធ្វើឱ្យគម្រោងមិនអាចសម្រេចបានទៅតាមផែនការកំណត់ ហើយចាំបាច់ត្រូវពន្យារពេលបន្ថែម ក្នុងការដាក់ឱ្យដំណើរការជាផ្លូវការ។ ការប្រើប្រាស់ប្រព័ន្ធមួយចំនួននៅមានកម្រិតនៅឡើយ ដោយសារការយល់ដឹង និងការផ្សព្វផ្សាយអំពីប្រព័ន្ធនៅមិនទាន់មានភាពទូលំទូលាយ។ ការរៀបចំក្របខណ្ឌបទប្បញ្ញត្តិ ព្រមទាំងវិធាននិងនីតិវិធីផ្សេងៗ

ត្រូវការពេលវេលាច្រើនក្នុងការពិនិត្យលើគោលនយោបាយសំខាន់ៗ និងធ្វើបច្ចុប្បន្នកម្មដើម្បីឱ្យស្របទៅនឹងការវិវត្តឆាប់រហ័សនៃបច្ចេកវិទ្យាផ្នែកប្រព័ន្ធទូទាត់សងប្រាក់។ ដោយឡែកការយល់ដឹងរបស់មន្ត្រីជំនាញអំពីប្រព័ន្ធទូទាត់សងប្រាក់នៅមានកម្រិត ដែលតម្រូវឱ្យមានការបណ្តុះបណ្តាលជាប្រចាំ៕

ឈឈឈឈឈឈឈឈឈឈ

## តារាងឧបសម្ព័ន្ធ១ ៖ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធផាត់ទាត់ជាតិ

| គោលការណ៍ PFMI | គោរពបានល្អ | គោរពបានភាគច្រើន | គោរពបានខ្លះ | មិនគោរពបាន |
|---|---|---|---|---|
| គោលការណ៍ទី១ មូលដ្ឋានគតិយុត្ត | | ✓ | | |
| គោលការណ៍ទី២ អភិបាលកិច្ច | ✓ | | | |
| គោលការណ៍ទី៣ ក្របខណ្ឌសម្រាប់គ្រប់គ្រងហានិភ័យ | | | ✓ | |
| គោលការណ៍ទី៤ ហានិភ័យឥណទាន | ✓ | | | |
| គោលការណ៍ ទី៥ ប្រាតិភោគ | | ✓ | | |
| គោលការណ៍ ទី៦ ម៉ាជីន | | | | |
| គោលការណ៍ទី៧ ហានិភ័យសន្ទនីយភាព | ✓ | | | |
| គោលការណ៍ទី៨ ការទូទាត់បញ្ចប់ | | ✓ | | |
| គោលការណ៍ទី៩ សាច់ប្រាក់ទូទាត់ | ✓ | | | |
| គោលការណ៍ ទី១០ ការប្រគល់ឧបករណ៍ជារូបវន្ត | | | | |
| គោលការណ៍ ទី១១ មជ្ឈមណ្ឌលរក្សាមូលបត្រ | | | | |
| គោលការណ៍ ទី១២ ប្រព័ន្ធសម្រាប់ទូទាត់ដោះដូរតម្លៃ | | | | |
| គោលការណ៍ទី១៣ វិធាននិងនីតិវិធីអំពីការទូទាត់បរាជ័យរបស់អ្នកចូលរួម | ✓ | | | |
| គោលការណ៍ ទី១៤ វិយោគកម្ម និង ការបែងចែក | | | | |
| គោលការណ៍ទី១៥ ហានិភ័យធុរកិច្ច | ✓ | | | |
| គោលការណ៍ ទី១៦ ហានិភ័យការថែរក្សា និងការវិនិយោគ | ✓ | | | |
| គោលការណ៍ទី១៧ ហានិភ័យប្រតិបត្តិការ | | ✓ | | |
| គោលការណ៍ទី១៨ ការចូលជាសមាជិកប្រើប្រព័ន្ធ | ✓ | | | |
| គោលការណ៍ទី១៩ ការចាត់ថ្នាក់សមាជិកចូលរួម | ✓ | | | |
| គោលការណ៍ទី២០ ការតភ្ជាប់រវាង FMI | | | | |
| គោលការណ៍ទី ២១ ប្រសិទ្ធភាព និង ប្រសិទ្ធផល | ✓ | | | |
| គោលការណ៍ទី២២ វិធានទំនាក់ទំនង និងបទដ្ឋានស្តង់ដារ | | ✓ | | |
| គោលការណ៍ទី២៣ ការបង្ហាញវិធាននិងនីតិវិធី និងទិន្នន័យ | ✓ | | | |
| គោលការណ៍ទី២៤ ការបង្ហាញទិន្នន័យដោយមណ្ឌលទុកទិន្នន័យពាណិជ្ជកម្ម | | | | |

# តារាងឧបសម្ព័ន្ធ២ ៖ បញ្ជីរាយនាមគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

| ល.រ | គ្រឹះស្ថានស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ១ | នាមករណ៍៖ | គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០១.១៧ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ | |
| | អាស័យដ្ឋាន៖ | អគារលេខ ៧៩ BCEo ផ្លូវលេខ ១២៨ ភូមិទី២ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៨៦ ៣៩៣ ១៣៨ | |
| | សារអេឡិចត្រូនិក៖ | team.hr@edeel.com | |
| | គេហទំព័រ៖ | www.edeel.com | |
| | ពាណិជ្ជសញ្ញា៖ (ឃីហោគ្រឹះស្ថាន & ឃីហោផលិតផល) | | |
| ២ | នាមករណ៍៖ | គ្រឹះស្ថាន ស៊ីធេល ហ្វាយនែនសល សឺវីស ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០១.១៨ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ | |
| | អាស័យដ្ឋាន៖ | អគារលេខ១៤៩ ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ១៨ ៨ ៨០០ ៨០០ | |
| | សារអេឡិចត្រូនិក៖ | bestmpay@mpay.com.kh | |
| | គេហទំព័រ៖ | www.bestmpay.com | |
| | ពាណិជ្ជសញ្ញា៖ (ឃីហោគ្រឹះស្ថាន & ឃីហោផលិតផល) | | |
| ៣ | នាមករណ៍៖ | គ្រឹះស្ថាន យូប៊ីល ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០២.១៨ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ | |
| | អាស័យដ្ឋាន៖ (ឃីហោគ្រឹះស្ថាន & ឃីហោផលិតផល) | អគារលេខ B3&C3-1 ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៣៨ ៣៣០០ ៨០០០០ | |
| | សារអេឡិចត្រូនិក៖ | support@coobill.com.kh | |
| | គេហទំព័រ៖ | www.coobill.com.kh | |
| | ពាណិជ្ជសញ្ញា៖ (ឃីហោគ្រឹះស្ថាន & ឃីហោផលិតផល) | | |

| | | | |
|---|---|---|---|
| ៤ | នាមករណ៍៖ | គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៣.១៨ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ | |
| | អាស័យដ្ឋាន៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | អគារលេខ ៩៩-១០០ មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៩៩៩ ៦៣៩ | |
| | សារអេឡិចត្រូនិក៖ | info@truemoney.com.kh | |
| | គេហទំព័រ៖ | www.truemoney.com.kh | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ៥ | នាមករណ៍៖ | គ្រឹះស្ថាន លី ហួរ ផេ ប្រ៊ូ ភីអិលស៊ី | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៤.១៨ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ | |
| | អាស័យដ្ឋាន៖ | ដីឡូត៍លេខ ២៤៣-២៤៤ ការិយាល័យ (១៥C-៤១C) ផ្លូវលេខ៥៩៨ សង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៨៧ ៦០១ ១១១ | |
| | សារអេឡិចត្រូនិក៖ | info@lyhourpay.com | |
| | គេហទំព័រ៖ | www.lyhourpay.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ៦ | នាមករណ៍៖ | គ្រឹះស្ថាន ស្ពីត ផេ ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៥.១៨ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ | |
| | អាស័យដ្ឋាន៖ | អគារលេខ ១៥៩-១៦១ ជាន់ទី៣ ផ្លូវលេខ១១៣ សង្កាត់បឹង-កេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៧០ ៩៩៧ ៧៧៥ | |
| | សារអេឡិចត្រូនិក៖ | cfo@speedpayplc.com | |
| | គេហទំព័រ៖ | www.speedpayplc.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| | | | |
|---|---|---|---|
| ៧ | នាមករណ៍៖ | គ្រឹះស្ថាន កាណាឌីយ៉ា ម៉ូបែល ម៉ាន់នី ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៦.១៨ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | វិមានកាណាឌីយ៉ា លេខ៣១៥ ជាន់ទី២៧ មហាវិថីព្រះមុន្នីវង្ស កែងវិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៩៨៩ ៨០៩ | |
| | សារអេឡិចត្រូនិក៖ | info@darapay.com.kh | |
| | គេហទំព័រ៖ | www.darapay.com.kh | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | DARAPay™ រហ័ស សុវត្ថិភាព គ្រប់ទីកន្លែង | DARA Pay |
| ៨ | នាមករណ៍៖ | គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៧.១៨ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | ខុនដូកាសា មេរីឌាន អគារ Orient ជាន់ទី២ លេខ A0១-0១ អាគារលេខ០១ ផ្លូវហាវើក កោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៩០១ ៧៨៨ | |
| | សារអេឡិចត្រូនិក៖ | info@ipay88.com.kh | |
| | គេហទំព័រ៖ | www.ipay88.com.kh | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | ipay88 | ipay88 |
| ៩ | នាមករណ៍៖ | គ្រឹះស្ថាន ផាយ ផេ ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៨.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | ផ្ទះលេខ២០ ផ្លូវលេខ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៩៨៨ ៩៨៩ | |
| | សារអេឡិចត្រូនិក៖ | info@pipay.com | |
| | គេហទំព័រ៖ | www.pipay.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | Pi Pay | |

| | | | |
|---|---|---|---|
| ១០ | នាមករណ៍៖ | គ្រឹះស្ថាន ជានស៊ូ អ៊ិនធើណេសិនណល ថេកណឡជី ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៩.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | អាគារលេខ៩៨៤ ផ្លូវលេខ១២៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៩៦ ៥៥៥ ០៨៨៨ | |
| | សារអេឡិចត្រូនិក៖ | មិនមាន | |
| | គេហទំព័រ៖ | www.vipaylife.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១១ | នាមករណ៍៖ | គ្រឹះស្ថាន បងឡួយ ផេមិន ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០១០.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | ផ្ទះលេខ៨៧ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៥៣២ ០៨៨៨ | |
| | សារអេឡិចត្រូនិក៖ | contact@bongloy.com | |
| | គេហទំព័រ៖ | www.bongloy.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១២ | នាមករណ៍៖ | គ្រឹះស្ថាន អេស៊ា វៃស អិចប្រេស ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០១១.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | ផ្ទះលេខ B២-០៣៥-០៣៦ ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៩៩ ៦៦៦ ៦៧៨ | |
| | សារអេឡិចត្រូនិក៖ | info@asiaweiluy.com | |
| | គេហទំព័រ៖ | www.asiaweiluy.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| | | | |
|---|---|---|---|
| ១៣ | នាមករណ៍៖ | គ្រឹះស្ថាន ហួយវ័ន ផេ ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០១២.១៨ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | អគារលេខ៦២ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ២៣១ ៩៩៩ | |
| | សារអេឡិចត្រូនិក៖ | 182828164@huione.com | |
| | គេហទំព័រ៖ | www.7572.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | HUIONE PAY | |
| ១៤ | នាមករណ៍៖ | គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិន សឹលូសិន ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០១៣.១៨ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន៖ | អគារលេខ១៩៩ ផ្លូវលេខ២៤៥ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៦៨៦ ៨៨៦៨ | |
| | សារអេឡិចត្រូនិក៖ | មិនមាន | |
| | គេហទំព័រ៖ | www.emoney.com.kh | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | money | money |
| ១៥ | នាមករណ៍៖ | គ្រឹះស្ថាន ដ្រាហ្គនហ្វ្លាយ ហ្វីនថេក (ខេមបូឌា) ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០១.១៩ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ | |
| | អាសយដ្ឋាន៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | អគារ ROSE GARDEN លេខ២៥២ ជាន់ផ្ទាល់ដី ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៩៨ ២១៨ ៥៥៥ | |
| | សារអេឡិចត្រូនិក៖ | enquiry@dragonfly.com.kh | |
| | គេហទំព័រ៖ | www.dragonfly.com.kh | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | dragonfly FINTECH | Payluy |

| | | | |
|---|---|---|---|
| ១៦ | នាមករណ៍៖ | គ្រឹះស្ថាន ដាយនែមីក ផេមិន ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០២.១៩ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ | |
| | អាស័យដ្ឋាន៖ | អគារលេខ៣១៥ (វិមានកាណាឌីយ៉ា) ជាន់ទី៣ តូប០៣-០៥ មហាវិថីព្រះមុន្នីវង្ស កែងផ្លូវព្រះអង្គឌួង ភូមិ១ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៩៨៩ ១៨៦ | |
| | សារអេឡិចត្រូនិក៖ | dp.dynamicg.com | |
| | គេហទំព័រ៖ | www.dynamic-payment.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១៧ | នាមករណ៍៖ | គ្រឹះស្ថាន ដាប់បែលយូ អាយ ប៊ី អេស.ខេអេច.ផេមិន សឺវីស ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៣.១៩ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ | |
| | អាស័យដ្ឋាន៖ | ផ្ទះលេខ១៤ ផ្លូវសភាជាតិ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៨១ ៩៩៩ ០៦៩ | |
| | សារអេឡិចត្រូនិក៖ | info@m.wibs-khplc.com | |
| | គេហទំព័រ៖ | www.wibs-khplc.com | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១៨ | នាមករណ៍៖ | គ្រឹះស្ថាន តារាសាគរ ផេ ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៥.១៩ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ | |
| | អាស័យដ្ឋាន៖ | អគារលេខ i៨៦ D.I Riviera វិថី Road Park កោះពេជ្រ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ២៣ ៩៩៤ ២២៧ | |
| | សារអេឡិចត្រូនិក៖ | មិនមាន | |
| | គេហទំព័រ៖ | មិនមាន | |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| | | |
|---|---|---|
| ១៩ | នាមករណ៍៖ | គ្រឹះស្ថាន បៃ សេន ថេកណឡជី ម.ក |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.00៦.១៩ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ |
| | អាសយដ្ឋាន៖ | Elite Town លេខ 0៥ ផ្លូវ Stanford សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៩៦ ៩៩៨ ៩៨៩៨ |
| | សារអេឡិចត្រូនិក៖ | មិនមាន |
| | គេហទំព័រ៖ | មិនមាន |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | |
| ២០ | នាមករណ៍៖ | គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.00៧.១៩ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ |
| | អាសយដ្ឋាន៖ | ផ្ទះលេខ៥៤B (ជាន់ផ្ទាល់ដី និងជាន់ទី១) ផ្លូវលេខ៩៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៧0 ៥៣៥ 0៩៥ |
| | សារអេឡិចត្រូនិក៖ | មិនមាន |
| | គេហទំព័រ៖ | មិនមាន |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | |
| ២១ | នាមករណ៍៖ | គ្រឹះស្ថាន ផារ៉ាហ្គុន ផេម៉ិន ស៊ើវីស ម.ក |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.00១.២0 ថ្ងៃទី១៣ ខែមករា ឆ្នាំ២0២0 |
| | អាសយដ្ឋាន៖ | អគារលេខ២១៦ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ១២ ៤៥៦ ២៣៧ |
| | សារអេឡិចត្រូនិក៖ | មិនមាន |
| | គេហទំព័រ៖ | មិនមាន |
| | ពាណិជ្ជសញ្ញា៖ (យីហោគ្រឹះស្ថាន & យីហោផលិតផល) | |

| | | | |
|---|---|---|---|
| ២២ | នាមករណ៍៖ | គ្រឹះស្ថាន ឃេស អ៊ិននើវេសិន ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០២.២០ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ | |
| | អាស័យដ្ឋាន៖ | អគារលេខ១០៥ ជាន់ទី៤ ផ្លូវ១៩៨៤A សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ១០ ៧៧៧ ៧០៨ | |
| | សារអេឡិចត្រូនិក៖ | support@kesspay.io | |
| | គេហទំព័រ៖ | kessinnovation.io | |
| | ពាណិជ្ជសញ្ញា៖ (ឈ្មោះគ្រឹះស្ថាន & ឈ្មោះផលិតផល) | KESS PAY | |
| ២៣ | នាមករណ៍៖ | គ្រឹះស្ថាន ជីប៊ីស៊ីអាយ វេនឈ័រ ម.ក | |
| | អាជ្ញាបណ្ណធនាគារជាតិនៃកម្ពុជា៖ | អ.០០៣.២០ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ | |
| | អាស័យដ្ឋាន៖ | អគារលេខ B2-033 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | |
| | លេខទូរស័ព្ទទំនាក់ទំនង៖ | (+៨៥៥) ៧០ ៣៣៣ ៥៣០ | |
| | សារអេឡិចត្រូនិក៖ | kh@gbci.vc | |
| | គេហទំព័រ៖ | www.fincy.com | |
| | ពាណិជ្ជសញ្ញា៖ (ឈ្មោះគ្រឹះស្ថាន & ឈ្មោះផលិតផល) | GBCI ក្រុមហ៊ុន ជីប៊ីស៊ីអាយ វេនឈ័រ ម.ក GBCI VENTURES PLC | |